N. 13
08-4-02

# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៥-៣-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៥៩ ស្ដីពីការតែងតាំងឯកឧត្ដម ០២រូប ជាទីប្រឹក្សាសម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភានៃ ព្រះរាជាណាចក្រកម្ពុជា | ៧៩០ |
| ២០-៣-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៧៦ ស្ដីពីការតែងតាំងលោក **ខាំ សុផល** ជាឧបការីប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា | ៧៩១ |
| ២០-៣-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៧៧ ស្ដីពីការតែងតាំងលោកស្រី **ឈុន ដាលីណា** ជាឧបការីប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា | ៧៩២ |
| ២៦-៣-២០០២ | -ព្រះរាជក្រឹត្យនស/រកត/០៣០២/០៧៩ស្ដីពីការបំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ជូនសមាជិកសមាជិកាព្រឹទ្ធ សភា ចំនួន ០៧រូប | ៧៩៣ |
| ២៨-៣-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៨០ស្ដីពីការតែងតាំងលោក **យ៉ាំ ស៊ុយសាំង** ជាឧកញ៉ា | ៧៩៥ |
| ៣០-៣-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៨២ ស្ដីពីការប្រោសព្រះរាជមាន ចំពោះឧកញ៉ា **ម៉ែន សារុន** ប្រធានក្រុមហ៊ុន ម៉ែន សារុន នីហ័រណ អាហ័រណនូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** | ៧៩៦ |
| ៣០-៣-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៨៣ ស្ដីពីការប្រោសព្រះរាជទាន ចំពោះឧកញ៉ា **លី យ៉ុងផាត់** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** | ៧៩៧ |
| ៣០-៣-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៨៤ ស្ដីពីការតម្លើងឋានៈ លោកជំទាវ **ឡូ សុខា** ជំនួយការសម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល កម្ពុជាមានឋានៈស្មើអគ្គនាយក | ៧៩៨ |
| ៣០-៣-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៨៥ ស្ដីពីការតែងតាំងអ្នកអង្គម្ចាស់ **នរោត្ដម ទ៉ាវ់ទ៉ាវិ** ជាទីប្រឹក្សាផ្ទាល់ស្ដេចក្រុមឃុន ស៊ីសុវត្ថិ ជីវ៉នមុនីរក្ស អនុប្រធានទី១ព្រឹទ្ធសភា | ៧៩៩ |

# ខ


| | | |
|---|---|---|
| ០៤-៤-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៨៦ ស្ដីពីការតែងតាំងលោក **ហែម ថេង** ជាឧកញ៉ា | ៨០០ |
| ០៣-៤-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៨៧ ស្ដីពីការបំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ជូនមន្ត្រីជាន់ខ្ពស់០៦រូបនៃខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី | ៨០១ |
| ០៣-៤-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៨៨ ស្ដីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **យុទ្ធ ភូថង** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** | ៨០២ |
| ០៣-៤-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៨៩ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរតាម សញ្ជាតូបនីយកម្មដល់លោក **វូ ឈីងលាង** ( WU CHING LIANG ) សញ្ជាតិដើមចិន | ៨០៣ |
| ០៥-៤-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/០៤០២/០៩១ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរតាម សញ្ជាតូបនីយកម្មដល់លោក **ហូរ ស៊ីនធាន** (HO CHIN TIEN ) សញ្ជាតិដើមចិន | ៨០៤ |


## II- រាជរដ្ឋាភិបាល

### ១_ អនុក្រឹត្យ


| | | |
|---|---|---|
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ២៦អនក្រ បក ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ | ៨០៥ |
| ០៥-៤-២០០២ | - អនុក្រឹត្យលេខ ២៧ អនក្រ បក ស្ដីពីការផ្ទេរឥណទានថវិកា | ៨២៤ |
| ០៨-៤-២០០២ | - អនុក្រឹត្យលេខ ២៨អនក្រ បក ស្ដីពីការបង្កើតវិទ្យាស្ថានក្រុងអង្គរ | ៨២៦ |
| ០១-៤-២០០២ | - អនុក្រឹត្យលេខ ១៥៦ អនក្រ តត ស្ដីពីការជូនមេដាយការងារ | ៨២៩ |
| ០១-៤-២០០២ | - អនុក្រឹត្យលេខ ១៥៧ អនក្រ តត ស្ដីពីការតែងតាំងមន្ត្រីរាជការ | ៨៣០ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៥៨ អនក្រ តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៣១ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៥៩ អនក្រ តត ស្ដីពីការជូនមេដាយសហមេត្រី | ៨៣២ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦០ អនក្រ តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៨៣៣ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦១ អនក្រ តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៣៤ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦២ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៨៣៥ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦៣ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៨៣៧ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦៤ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៨៣៩ |

# គ


| | | |
|---|---|---|
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦៥ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៨៤២ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦៦ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៨៤៥ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦៧ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា | ៨៤៧ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦៨ អនក្រ.តត ស្ដីពីការរៀបចំសមាសភាពគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា | ៨៤៩ |
| ០២-៤-២០០២ | - អនុក្រឹត្យលេខ ១៦៩ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៨៥២ |
| ០៤-៤-២០០២ | - អនុក្រឹត្យលេខ ១៧០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៥៣ |
| ០៤-៤-២០០២ | - អនុក្រឹត្យលេខ ១៧១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៥៤ |
| ០៤-៤-២០០២ | - អនុក្រឹត្យលេខ ១៧២ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៨៥៥ |
| ០៤-៤-២០០២ | - អនុក្រឹត្យលេខ ១៧៣អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៨៦០ |
| ០៤-៤-២០០២ | - អនុក្រឹត្យលេខ ១៧៤ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៨៦២ |
| ០៤-៤-២០០២ | - អនុក្រឹត្យលេខ ១៧៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៦៤ |
| ០៤-៤-២០០២ | - អនុក្រឹត្យលេខ ១៧៦ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ | ៨៦៦ |
| ០៤-៤-២០០២ | - អនុក្រឹត្យលេខ ១៧៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ | ៨៦៨ |
| ០៥-៤-២០០២ | - អនុក្រឹត្យលេខ ១៧៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៦៩ |
| ០៨-៤-២០០២ | - អនុក្រឹត្យលេខ ១៧៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ | ៨៧០ |
| ០៨-៤-២០០២ | - អនុក្រឹត្យលេខ ១៨០អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៧១ |
| ០៨-៤-២០០២ | - អនុក្រឹត្យលេខ ១៨១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៧៣ |
| ០៨-៤-២០០២ | - អនុក្រឹត្យលេខ ១៨២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៧៥ |
| ០៨-៤-២០០២ | - អនុក្រឹត្យលេខ ១៨៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៧៧ |
| ០៨-៤-២០០២ | - អនុក្រឹត្យលេខ ១៨៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៨៧៩ |


## ២. សេចក្ដីសំរេច


| | | |
|---|---|---|
| ២៦-៣-២០០២ | -សេចក្ដីសំរេចលេខ២១ សសរ ស្ដីពីការបង្កើតគណកម្មការស្តារនិង រៀបចំកែលំអកំណាត់ ផងស្ទឹងសៀមរាប | ៨៨១ |
| ០១-៤-២០០២ | -សេចក្ដីសំរេចលេខ ២២សសរ ស្ដីពីការបង្កើតគណកម្មការចំរុះសំរាប់ដោះស្រាយករណីរោងចក្រហ្គោលហ្វម អ៊ិនធឺប្រាយគ្លីតធីលីមីធីត | ៨៨៤ |

០៨-៤-២០០២ -សេចក្តីសំរេចលេខ២៣ សសរ ស្តីពីការបង្កើតគណកម្មការអន្តរក្រសួង ដើម្បីរៀបចំនិងចូលរួមពិព័រណ៍ពាណិជ្ជកម្មនៅបណ្តាប្រទេសអាស៊ាន ៨៨៦

### ៣. សារាចរណែនាំ

០១-៤-២០០២ -សារាចរណែនាំ លេខ ០៦ សរណន ស្តីពីការរៀបចំបុណ្យវិសាខបូជា និងពិធីច្រត់ព្រះនង្គ័ល ៨៩០

## III-ការងារបណ្តាក្រសួង

### ១. ទីស្តីការគណៈរដ្ឋមន្ត្រី

០២-៤-២០០២ - សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការបង្កើតក្រុមការងារអភិវឌ្ឍន៍សង្គមកិច្ចនៅទីស្តីការគណៈរដ្ឋមន្ត្រី ៨៩៤

### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

០៣-៤-២០០២ -ប្រកាសលេខ ២៤៦សហវ ស្តីពីការផ្លាស់ប្តូរសមាជិកក្រុមការងារសំរាប់គំរោងអភិវឌ្ឍន៍កសិកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445CAM (SF) ៨៩៦

០៣-៤-២០០២ -ប្រកាសលេខ ២៤៨សហវ ស្តីពីការបង្កើតគណកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ៨៩៨

### ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៤-៤-២០០២ - ប្រកាសលេខ ១១១ Moc/M2002 ស្តីពីស្ថានភាពរោងចក្រកាត់ដេរ Eastfull Footwear MFG Co,Ltd ៩០២

### ៤. អន្តរក្រសួងមហាផ្ទៃ និង ក្រសួងផែនការ

០៤-៤-២០០២ -ប្រកាសអន្តរក្រសួងលេខ៥៥ ប្រក ស្តីពីការប្រើប្រាស់សេចក្តីណែនាំពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងទំរង់គំរូសៀវភៅផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគឃុំ សង្កាត់ ៣ឆ្នាំរំកិល(២០០៣-២០០៥ ) ៩០៤

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៥៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជបរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំងឯកឧត្តម ចំនួន ០២ រូប ដូចខាងក្រោម ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស :

១- ឯកឧត្តម **ផាន់ ចាន់ធុល** ទទួលបន្ទុកការងារអភិវឌ្ឍន៍កសិកម្ម

២- ឯកឧត្តម **រស់ សារីទ្ធ** ទទួលបន្ទុកការងារសង្គមកិច្ច

**មាត្រា ២ :** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៧៦ ច.ល

ដើម្បីចម្លងចែក

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០២*

រាជធានីភ្នំពេញ . ថ្ងៃទី ០២ ខែ[illegible] ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រាល-០២.០៣.០០៦៩

[illegible] តាន់

នស/រកត/០៣០២/០៧៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១៨៥ រស ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០២

-យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា១** .- តែងតាំងលោក **ខា សុផល** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៧៧៧ ច.ល

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិនា ឆ្នាំ ២០០២

៣៧០-០២.០៣.០០៧៦

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឹ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៧៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធាន រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១៨៧ រស ចុះថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០២

-យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា១** .- តែងតាំងលោកស្រី **ឈុន ជាលីណា** ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៧៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិនា ឆ្នាំ ២០០២

ពរស.០២.០៣.០០៩៧

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៧៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកមី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន ០៧ រូប ដូចមានរាយនាមខាងក្រោម :

**ក_ ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ស៊ិន** | **ពិនសេន** | អនុប្រធានគណៈកម្មការសេដ្ឋកិច្ច និងផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន |
| ២- ឯកឧត្តម | **ជុំ** | **ចន់** | លេខាធិការគណៈកម្មការនីតិកម្ម |
| ៣- ឯកឧត្តម | **និត** | **រាម** | លេខាធិការគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិ-ការអន្តរជាតិ ឃោសនាការ និងពត៌មាន |

ខ_ ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១- ឯកឧត្តម សោម សុជា សមាជិក

២- ឯកឧត្តម អ៊ុំ សារីទ្ធ សមាជិក

៣- លោកជំទាវ ឡាក់ អួន សមាជិកា

៤- ឯកឧត្តម ជ័យ សារ៉ុន សមាជិក

**មាត្រា ២ :** ប្រធានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

លេខ : ៧៧ ច.ល

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០២

៣៧៤.០២.០៣.០០៩៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឈាង ឌាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៨០

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

## តែងតាំង

**លោក យាំ ស៊ុយសាំង**

## ជា

## ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០២

៣រល.០២.១៣.០០៩០

លេខ : ៧/៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ០៤ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សោ ខាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៩២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

ឧកញ៉ា ម៉ែន សារុន ប្រធានក្រុមហ៊ុន ម៉ែន សារុន នីហរ័ណ អាហរ័ណ

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

លេខ : ៧៣ ច.ល

៣ពស-០២.០៣-០០៥២

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិនា ឆ្នាំ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០១ ខែ (មេសា) ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៤៣

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

ឧកញ៉ា **លី យ៉ុងផាត់**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ព្រះហស្តលេខា និង ព្រះរាជលញ្ចករ

**នរោត្តម សីហនុ**

លេខ : ៣៩៤ ច.ល

ដើម្បីចម្លងចែក

៣៩ល-០២.០៣-០០៩៣

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិនា ឆ្នាំ២០០២

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ (មេសា) ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង ពាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៩៤

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តម្លើងឋានៈលោកជំទាវ **ឡូរី សុខា** ជំនួយការសម្តេចនាយរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២:** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៧៥ ច.ល

ចរណ.០២.០៣-០០៩៤

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០០២*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៨៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងអ្នកអង្គម្ចាស់ នរោត្តម ចាន់ចារី ជាទីប្រឹក្សាផ្ទាល់ស្តេចក្រុមឃុន ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភា ទទួលបន្ទុកផ្នែកការពារជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣៤.០២.០៣.០០៩៥

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិនា ឆ្នាំ២០០២

លេខ: ៧៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៨៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

**តែងតាំង**

**លោក ហែម ថេង**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣៤៧.០២.០៤.០០៦

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២*

លេខ : ៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៨៧

យើង

## ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីជាន់ខ្ពស់ចំនួន ០៦ រូប នៃខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចការងារបំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក/ <u>គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា</u>

១- ឯកឧត្តម **ខិម យ៉ិនឡៀង** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី

២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី

ខ/ <u>គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ អស្សឫទ្ធិ</u>

១- ឯកឧត្តម **ស៊ុម មាន** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី

២- ឯកឧត្តម **សម សុគ្គា** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី

៣- ឯកឧត្តម **គៀង សាវុធ** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី

៤- ឯកឧត្តម **ហេង តៃគ្រី** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

លេខ : ៩១ ច.ល

៣៤៣-០២.០៤.០០៨៧

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៨៨

យើង

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្ដម **យុទ្ធ ភូថង**

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

**ព្រះហស្ដលេខា និង ព្រះរាជលញ្ឆករ**

**នរោត្ដម សីហនុ**

លេខ : ៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

៣រល. ០២.០៤.០០៩៥

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០០២*

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៨៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វូ ឈីងលាង** ( WU CHING LIANG ) សញ្ជាតិដើមចិន កើតថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៥៥ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ៥៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សារី តាន់**

៣៤៧.០២.០៤.០០៩៥

*ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ. ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២*

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៩៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហូរ ស៊ីនធាន** ( HO CHIN TIEN ) សញ្ជាតិដើមចិន កើតថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៤៨ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

លេខ : ៨៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

៣៤៧.០២.០៤.០០១០១

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚*៚៚៚

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

យោងសារតិអង្គប្រជុំលើកទី១១ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី១៣ ១៤ ខែមីនា ឆ្នាំ២០០២

- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ស្របតាមមាត្រា៧៣ មាត្រា៧៩ មាត្រា៨១ មាត្រា៨២ និង មាត្រា៨៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ២.-**

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវបានបង្កើតឡើងដែលរួមមានបទប្បញ្ញត្តិ និងនីតិវិធីទាក់ទងទៅនឹងការងារដូចខាងក្រោម:

១/ ថវិកាឃុំ សង្កាត់

២/ ប្រពន្ធ័គណនេយ្យនិងប្រព័ន្ធទូទាត់សំរាប់ឃុំ សង្កាត់

៣/ ការគ្រប់គ្រងចំណាយរបស់ឃុំ សង្កាត់

៤/ ទ្រព្យសម្បត្តិឃុំ សង្កាត់

៥/ សវនកម្ម និង របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់ ។

## ជំពូកទី ២

## ថវិកាឃុំ សង្កាត់

### ផ្នែកទី ១

### ចំណូល ចំណាយរបស់ឃុំ សង្កាត់

**មាត្រា ៣.-**

ថវិកាឃុំ សង្កាត់ ជាលិខិតគតិយុត្តិដែលគ្រោង និង អនុញ្ញាតចំណូល និង ចំណាយដោយផ្អែកលើមូលដ្ឋានឆ្នាំ ។

ឆ្នាំថវិការបស់ឃុំ សង្កាត់ ចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា និង បញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ។

ថវិកាឃុំ សង្កាត់ត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយរបស់ឃុំ សង្កាត់ដោយមិនគិតដល់ប្រភពដើម ឬ ចរិតលក្ខណៈឡើយ ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងរាល់ការចំណាយជាអាទិភាពនៃផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

ថវិកាឃុំ សង្កាត់ត្រូវបានរៀបចំឡើងជាពីរផ្នែក:

- ផ្នែកទី១: ចំណូល និង ចំណាយចរន្ត

- ផ្នែកទី២: ចំណូល និង ចំណាយមូលធន។

ចំណូលសរុបត្រូវតុល្យភាពនឹងចំណាយសរុប។ អតិរេកក្នុងផ្នែកទី១ ត្រូវបានប្រើប្រាស់ជាគុណប្រយោជន៍ក្នុងផ្នែកទី២។

ចំណូលមូលធនមិនត្រូវបានប្រើប្រាស់សំរាប់ធ្វើហិរញ្ញប្បទានដល់ចំណាយចរន្ត លើកលែងតែមានការអនុញ្ញាតដោយបទប្បញ្ញត្តិដោយឡែក។

**មាត្រា ៥.-**

ចំណាយចរន្តចែកចេញជា ៧ប្រភេទ :

ប្រភេទ១- ចំណាយបៀវត្ស និង ប្រាក់បំណាច់

ប្រភេទ២- ចំណាយរដ្ឋបាលទូទៅ

ប្រភេទ៣- ចំណាយសេវាសាធារណៈ

ប្រភេទ៤- ចំណាយសំរាប់មុខងារជាភ្នាក់ងារ

ប្រភេទ៥- ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច

ប្រភេទ៦- ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច

ប្រភេទ៧- ចំណាយមិនបានគ្រោងទុក

**មាត្រា ៦.-**

ចំណូលចរន្តចែកចេញជា ៥ប្រភេទ :

ប្រភេទ១- ចំណូលពន្ធមូលដ្ឋាន

ប្រភេទ២- ចំណូលមិនមែនសារពើពន្ធ

ប្រភេទ៣- ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សំរាប់រដ្ឋបាលទូទៅ

ប្រភេទ៤- ចំណូលពីការអនុវត្តន៍មុខងារជាភ្នាក់ងារ

ប្រភេទ៥- ចំណូលចរន្តផ្សេងៗ ។

**មាត្រា ៧.-**

ចំណាយមូលធនចែកចេញជា ២ប្រភេទ :

ប្រភេទ១- ចំណាយវិនិយោគផ្នែករដ្ឋបាល

ប្រភេទ២- ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន។

**មាត្រា ៨.-**

ចំណូលមូលធនចែកចេញជា ៤ប្រភេទ :

ប្រភេទ១- ចំណូលមូលនិធិបំរុងដូចមានចែងក្នុងមាត្រា ២២នៃអនុក្រឹត្យនេះ

ប្រភេទ២- ចំណូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សំរាប់អភិវឌ្ឍន៍មូលដ្ឋាន

ប្រភេទ៣- ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានទៅក្នុងតំលៃគំរោង

ប្រភេទ៤- ចំណូលមូលធនផ្សេងៗ ។

**មាត្រា ៩.-**

ចំណាយទាំងឡាយខាងក្រោមនេះ ត្រូវបានចាត់ទុកជាចំណាយចាំបាច់ របស់ឃុំ សង្កាត់ ដែលត្រូវឆ្លុះបញ្ចាំងជាអាទិភាពក្នុងថវិកា :

១- ចំណាយបៀវត្ស និង ប្រាក់បំណាច់

២- ចំណាយទុកដាក់ថែរក្សាឯកសារ

៣- ចំណាយលើថ្លៃឈ្នួលថែទាំទីស្នាក់ការឃុំ សង្កាត់

៤- ចំណាយថែទាំ និង ប្រតិបត្តិការនៃហេដ្ឋារចនាសម្ព័ន្ធ ដែលឃុំ សង្កាត់ទទួលខុសត្រូវ

៥- ចំណាយរៀបចំផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់

៦- ចំណាយបន្តគំរោងការវិនិយោគកំពុងដំណើរការ

៧- ចំណាយចាំបាច់ដទៃទៀតដែលស្របតាមច្បាប់ ឬបទបញ្ញាដែលបានកំណត់ ។

**មាត្រា ១០.-**

ចំណូលរបស់ឃុំ សង្កាត់ត្រូវបានកំណត់ និងប្រមូល តាមបទប្បញ្ញត្តិដោយឡែក ។

ចំណាយរបស់ឃុំ សង្កាត់ត្រូវបានសន្យា ជំរះបញ្ជី ធ្វើអាណត្តិកិច្ច និង ទូទាត់ ដោយមានលិខិតយុត្តិការត្រឹមត្រូវច្បាស់លាស់ តាមនិតិវិធី និងបទប្បញ្ញត្តិ ដូចមានចែងក្នុង ជំពូកទី២ ជំពូកទី៣ និង ជំពូកទី៤ នៃអនុក្រឹត្យនេះ ។

ចំណាយប្រតិបត្តិការ និង ការថែទាំហេដ្ឋារចនាសម្ព័ន្ធ ត្រូវរ៉ាប់រងដោយខ្ទង់ចំណូលដែលបានមកពីបន្ទុកអ្នកប្រើប្រាស់ និង ចំណូលដែលទទួលបានពីមុខងារជាភ្នាក់ងារ ។

## ផ្នែកទី ២
## ការរៀបចំ និង ការអនុម័តថវិកា

**មាត្រា ១១.-**

គំរោងថវិកាត្រូវរៀបចំឡើង ក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពិគ្រោះកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យនិង អនុម័ត ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគំរោងថវិកានាកិច្ចប្រជុំជាសាធារណៈអោយបានមុន ថ្ងៃទី៣១ ខែតុលា ។ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវអនុម័តគំរោងថវិកាតាមផ្នែកនិងតាមប្រភេទនិមួយៗ ។

**មាត្រា ១២.-**

មេឃុំ ចៅសង្កាត់ត្រូវធានាអោយមានការចូលរួមពីសាធារណជនមូលដ្ឋានក្នុងដំណើរការរៀបចំថវិកា តាមរយៈវិធានការទាំងឡាយដូចខាងក្រោម:

- គំរោងថវិកាត្រូវតែប្រកាសផ្សាយជាសាធារណៈ យ៉ាងតិច២សប្តាហ៍ មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវបើកចំហដល់ សាធារណជនដែលចាប់អារម្មណ៍លើការពិនិត្យគំរោងថវិកានេះ
- ប្រជាពលរដ្ឋត្រូវតែបានផ្តល់កាលានុវត្តភាពក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលសំរេចលើគំរោងថវិកា ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតនូវយន្តការផ្សេងៗ ដើម្បីជំរុញអោយមានការចូលរួមពីសាធារណជន លើកិច្ចការមូលដ្ឋាន។

**មាត្រា ១៣.-**

មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនគំរោងថវិកាដែលបានអនុម័តរួចទៅអភិបាលខេត្ត ក្រុងអោយបានមុនថ្ងៃ ទី៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់ ។

គំរោងថវិកាត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម:

- របាយការណ៍សង្ខេបស្តីពីមូលដ្ឋានក្នុងការរៀបចំចំណូល និង ចំណាយ ព្រមទាំងកិរិតចូលរួម របស់ ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកានៃឆ្នាំដំណើរការ
- តារាងសង្ខេប នៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ប្រសិនបើមាន
- កំណត់ហេតុ ស្តីពី កិច្ចប្រជុំ អនុម័តលើគំរោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៤.-**

អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគំរោងថវិកាអោយបានមុនថ្ងៃទី៣០ ខែវិច្ឆិកា ។

ការត្រួតពិនិត្យអនុលោមភាពត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោម:

១-ទំរង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការរៀបចំថវិកា

២-តុល្យភាពថវិកា និង ការប្រើប្រាស់ចំណូលមូលធនដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ

៣-ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ដែលទទួលបាន

៤-ការគ្រោងគណនេយ្យទានថវិកាទៅតាមគោលការណ៍ចំណាយចាំបាច់

៥-តំរូវការថវិកាវិនិយោគ សំរាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការ របស់ឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុងមិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជំរើសនៃការចំណាយដែលបានសំរេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្រៅពីពិនិត្យលើល័ក្ខខ័ណ្ឌទាំងឡាយដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព ។

## មាត្រា ១៥.-

ប្រសិនបើ គំរោងថវិកាត្រូវបានបំពេញតាមល័ក្ខខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាព ដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ អភិបាលខេត្ត ក្រុង ត្រូវបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា និងចេញសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ ជូនមេឃុំ ចៅសង្កាត់ ។ សេចក្តីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារថវិកា ដែលមានហត្ថលេខាសង្ខេបរបស់ អភិបាលខេត្ត ក្រុង និងបោះត្រាលើទំព័រនីមួយៗ ។

អភិបាលខេត្ត ក្រុងត្រូវចំលងជូនសេចក្តីជូនដំណឹង ព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង ។

## មាត្រា ១៦.-

ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា អភិបាលខេត្ត ក្រុងត្រូវជូនដំណឹងបន្ទាន់ ជាលាយល័ក្ខអក្សរដល់មេឃុំ ចៅសង្កាត់ដោយបញ្ជាក់ពីមូលហេតុហើយណែនាំដល់មេឃុំ ចៅសង្កាត់អោយអនុវត្តវិធានការ កែតម្រូវ ។

មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យកែសំរួលគំរោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុង ហើយដាក់ជូន ក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តក្នុងរង្វង់១៥ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់អភិបាល ខេត្ត ក្រុង ។

បន្ទាប់ពីការពិភាក្សា មេឃុំ ចៅសង្កាត់ ផ្ញើគំរោងថវិកាកែតម្រូវជូនអភិបាលខេត្ត ក្រុង បញ្ជាក់ទទួលស្គាល់ ។

ប្រសិនបើ មេឃុំ ចៅសង្កាត់ ខកខានមិនបានបញ្ជូនគំរោងថវិកាដែលបានពិនិត្យឡើងវិញដល់អភិបាល ខេត្ត ក្រុង ក្នុងរង្វង់មួយខែបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងខាងលើ ឬ គំរោងថវិកាដែលបានពិនិត្យឡើងវិញនៅតែមិនទាន់ឆ្លើយតប បានទៅនឹងការត្រួតពិនិត្យអនុលោមភាព ពេលនោះអភិបាលខេត្ត ក្រុង មានសិទ្ធិចាត់វិធានការកែសំរួលចាំបាច់ មុនពេល បញ្ជាក់ទទួលស្គាល់លើគំរោងថវិកា ។អភិបាលខេត្ត ក្រុង ត្រូវជូនដំណឹងអំពីសេចក្តីសំរេចរបស់ខ្លួនដល់មេឃុំ ចៅសង្កាត់ មន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង តាមនីតិវិធីដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ។

ក្នុងករណីមានការមិនចុះសំរុងគ្នារវាងមេឃុំ ចៅសង្កាត់ ជាមួយអភិបាលខេត្ត ក្រុង មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូន ករណីនេះ ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យសំរេច ។ សេចក្តីសំរេច របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាត់ទុកជាការសំរេច ចុងក្រោយ ។

**មាត្រា ១៧.-**

ក្នុងករណី អភិបាលខេត្ត ក្រុង មិនបានបញ្ជាក់ទទួលស្គាល់លើគំរោងថវិកា មុនថ្ងៃទី០១ ខែមករានៃឆ្នាំ មេឃុំ ចៅសង្កាត់ត្រូវបានអនុញ្ញាតអោយអនុវត្តជាបណ្តោះអាសន្នលើចំណាយប្រចាំខែក្នុងកំរិត ១/១២ នៃថវិកាដែលបានអនុម័តឆ្នាំមុន និងលើការប្រមូលចំណូលរបស់ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដែលបានអនុម័ត ដូចឆ្នាំមុនដែរ ។

## ជំពូកទី ៣
## ការអនុវត្តន៍ថវិកា

**មាត្រា ១៨.-**

ថវិកាឃុំ សង្កាត់ អាចនឹងត្រូវបានកែតំរូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃ ល័ក្ខខ័ណ្ឌសេដ្ឋកិច្ច ឬ ហិរញ្ញវត្ថុ ដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃចំណូល និងចំណាយ ។

**មាត្រា ១៩.-**

ការកែតំរូវថវិកាត្រូវរៀបចំ ពិនិត្យ អនុម័ត និងបញ្ជាក់ទទួលស្គាល់ តាមនីតិវិធីដូចមានចែងក្នុងមាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ និងមាត្រា១៥នៃអនុក្រឹត្យនេះ ។

ប្រសិនបើ គោលបំណងនៃការកែតំរូវថវិកា គ្រាន់តែជាការវិភាជន៍ធនធានឡើងវិញ ក្នុងប្រភេទចំណាយតែមួយ ដោយមិនធ្វើអោយប្រែប្រួលចំនួនទឹកប្រាក់នៃប្រភេទចំណាយ ឬមិនធ្វើអោយប្រែប្រួលប្រភេទគំរោងវិនិយោគនៅក្នុងថវិកាដំបូងនោះ ពុំចាំបាច់សុំការបញ្ជាក់ទទួលស្គាល់ឡើងវិញពីអភិបាលខេត្ត ក្រុងទេ ។ ក្នុងករណីនេះ មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងដល់អភិបាល ខេត្ត ក្រុង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត ក្រុង អំពីការប្រែប្រួលធនធានវិភាជន៍ឡើងវិញមិនអោយយឺតជាង៥ថ្ងៃ បន្ទាប់ពីការពិភាក្សាសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២០.-**

ឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក មិនត្រូវលើស ៣% នៃថវិកាសរុប ។ ខ្ទង់ថវិកានៃចំណាយមិនបានគ្រោងទុកអាចត្រូវបានប្រើប្រាស់ សំរាប់ធានាចំពោះចំណាយទាំងឡាយណាដែលការវិភាជន៍មិនត្រូវបានកំណត់ជាក់លាក់នៅពេលឥណទានត្រូវបានអនុម័ត ឬសំរាប់ឥណទានបំពេញបន្ថែមជាគុណប្រយោជន៍ ដល់ប្រភេទចំណាយផ្សេងៗទៀតរបស់ឃុំ សង្កាត់ ។

មេឃុំ ចៅសង្កាត់ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សាឃុំ សង្កាត់មុនពេលសំរេចចិត្តលើការប្រើប្រាស់ឥណទានថវិកាចំណាយមិនបានគ្រោងទុក ។

**មាត្រា ២១.-**

នៅដំណាច់ឆ្នាំថវិកា គណនេយ្យករឃុំ សង្កាត់នៅរតនាគារខេត្ត ក្រុងត្រូវរៀបចំបិទបញ្ជី និងធ្វើរបាយការណ៍ស្ដី

គណនេយ្យករត្រូវធ្វើរបាយការណ៍បិទបញ្ជីជូនមេឃុំ ចៅសង្កាត់ដើម្បីផ្ទៀងផ្ទាត់គណនីថវិកា ជាមួយឃុំ សង្កាត់ ។ គណនេយ្យករ និងមេឃុំ ចៅសង្កាត់ ត្រូវពិនិត្យ កែតំរូវលេខនា និង ឯកភាពលើរបាយការណ៍បិទបញ្ជីនោះ ។

របាយការណ៍បិទបញ្ជីបង្ហាញនូវតួលេខអនុវត្តជាក់ស្តែង របស់ថវិកាព្រមទាំងទ្រព្យសម្បត្តិ និង ស្ថានភាពរតនៈវត្ថុ ដំណាច់ឆ្នាំរបស់ឃុំ សង្កាត់ ។

### មាត្រា ២២.-

មេឃុំ ចៅសង្កាត់ត្រូវដាក់របាយការណ៍បិទបញ្ជីជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ អនុម័ត ក្នុងខែមីនានៃឆ្នាំបន្ទាប់។ បន្ទាប់ពីការពិភាក្សា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តដោយបោះឆ្នោត លើសេចក្តីសំរេច ស្តីពីការបិទបញ្ជីថវិកា ។

សេចក្តីសំរេចស្តីពីការបិទបញ្ជីថវិកាត្រូវ:

១- បញ្ជាក់នូវចំណូល ចំណាយជាក់ស្តែងដែលសំរេចបានក្នុងឆ្នាំថវិកា

២- លុបចោលឥណទានថវិកាដែលមិនបានប្រើប្រាស់

៣- អនុញ្ញាតអោយផ្ទេរលទ្ធផលនៃឆ្នាំថវិកាទៅគណនី មូលនិធិបំរុង ។

បន្ទាប់ពីបានអនុម័តរួចយ៉ាងយូរ៧ថ្ងៃ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូន "សេចក្តីសំរេចស្តីពីការបិទបញ្ជីថវិកា "ទៅអភិបាលខេត្ត ក្រុង ដើម្បីពិនិត្យបញ្ជាក់ទទួលស្គាល់ដោយភ្ជាប់ជាមួយនូវ:

- របាយការណ៍បិទបញ្ជីគណនេយ្យ
- របាយការណ៍ ស្តីពី សកម្មភាពទូទៅនៃឃុំ សង្កាត់
- កំណត់ហេតុនៃការពិភាក្សាអនុម័តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

### មាត្រា ២៣.-

មូលនិធិបំរុងត្រូវប្រើប្រាស់សំរាប់ហិរញ្ញប្បទានដល់ចំណាយមូលធននៃថវិកាឆ្នាំក្រោយ ។

## ជំពូកទី ៣
## ប្រព័ន្ធគណនេយ្យនិងប្រព័ន្ធទូទាត់សំរាប់ឃុំ សង្កាត់

### មាត្រា ២៤.-

ប្រព័ន្ធគណនេយ្យឃុំ សង្កាត់ត្រូវបំរើដល់គោលបំណងទាំងឡាយដូចខាងក្រោម:

១- បញ្ជីការរាល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

២- ធ្វើរបាយការណ៍ហិរញ្ញវត្ថុជាក់ស្តែងអោយទាន់ពេលវេលា ដែលអាចជាកម្មវត្ថុសំរាប់ ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

៣- ផ្តល់មូលដ្ឋានសំរាប់តាមដានការអនុវត្តន៍ថវិការបស់ឃុំ សង្កាត់ ។

គណនេយ្យឃុំ សង្កាត់ រួមមាន:

ក៖ គណនេយ្យហិរញ្ញវត្ថុ : គណនា ចុះបញ្ជី និងធ្វើរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុ របស់ឃុំ សង្កាត់ ។

ខ៖ គណនេយ្យថវិកា : តាមដាន និងធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍ថវិកាដែលបានអនុម័ត ។

**មាត្រា ២៥.-**

គណនេយ្យហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ គឺផ្អែកលើមូលដ្ឋានសាច់ប្រាក់ និងតាមវិធីបញ្ជីកាទ្វេភាគ ។ មាតិកាគណនី ត្រូវស្របគ្នាជាមួយមាតិកាថវិការបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ណាដែលមានធនធានហិរញ្ញវត្ថុ ឬ សមត្ថភាពគ្រប់គ្រងមានកំរិតខ្សោយអាចប្រើប្រាស់មាតិកាគណនី និងមាតិកាថវិកាដែលមានលក្ខណៈសាមញ្ញ ។

**មាត្រា ២៦.-**

រតនាគារខេត្ត ក្រុងត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោម :

១- ប្រមូល ឬ ទទួលចំណូលរបស់ឃុំ សង្កាត់

២- ទូទាត់ចំណាយដែលបានចេញអាណត្តិដោយមេឃុំ ចៅសង្កាត់

៣- គ្រប់គ្រង និង បើកផ្តល់ថវិកាឃុំ សង្កាត់

៤- បញ្ជីកាប្រតិបត្តិការហិរញ្ញវត្ថុឃុំ សង្កាត់ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា២៥ នៃអនុក្រឹត្យនេះ

៥- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់

៦- ថែរក្សាទុកដាក់រាល់ឯកសារសក្ខីប័ត្រ និង បញ្ជីគណនេយ្យរបស់ឃុំ សង្កាត់ ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់ជាអាណាប័ក មានសិទ្ធិសំរេចអោយប្រមូលចំណូល សន្យាចំណាយ និង បញ្ជាចំណាយ ដោយផ្អែកលើថវិកាឃុំ សង្កាត់ដែលបានអនុម័ត ។

មេឃុំ ចៅសង្កាត់អាចផ្ទេរសិទ្ធិជាលាយល័ក្ខអក្សរ ក្នុងការសំរេចលើថវិកាទៅអោយ ជំទប់ ចៅសង្កាត់រង ណាមួយរបស់រដ្ឋបាលឃុំ សង្កាត់ ។ ការផ្ទេរសិទ្ធិជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់ ។

អាណាប័ក និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ ។

**មាត្រា ២៨.-**

សិទ្ធិបញ្ជាចំណាយ និង ការទូទាត់មិនត្រូវប្រគល់អោយមនុស្សតែម្នាក់ លើកលែងតែករណីទាំងឡាយដូចមានចែងក្នុងមាត្រា ៣១នៃអនុក្រឹត្យនេះ ។

មាត្រា ២៩.-

ឃុំ សង្កាត់នីមួយៗត្រូវបើកគណនីប្រាក់បញ្ញើមួយនៅរតនាគារខេត្ត ក្រុង ។ គណនីនេះត្រូវបានប្រើប្រាស់សំរាប់ទទួលចំណូល និងទូទាត់ចំណាយ ។

មាត្រា ៣០.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចអនុញ្ញាតដល់ឃុំ សង្កាត់ក្នុងការគ្រប់គ្រងទាំងស្រុង ឬមួយចំណែកនៃប្រតិបត្តិការសាច់ប្រាក់តាមរយៈគណនីបើកនៅធនាគារពាណិជ្ជប្រតិស្រុតណាមួយ ។

មាត្រា ៣១.-

ឃុំ សង្កាត់ត្រូវធ្វើការទូទាត់ដល់ចំណាយទាំងឡាយដែលមានចំនួនទឹកប្រាក់នៅក្រោមកំរិតមួយជាកំណត់ តាមនីតិវិធីបេឡាបុរេប្រទាន ។

មេឃុំ ចៅសង្កាត់ត្រូវតែងតាំងមន្ត្រីមួយរូបរបស់រដ្ឋបាលឃុំ សង្កាត់អោយទទួលខុសត្រូវក្នុងការគ្រប់គ្រងបេឡាបុរេប្រទាននេះ ។

បេឡាករបុរេប្រទានត្រូវទទួលខុសត្រូវលើសុវត្ថិភាពរបស់មូលនិធិ ព្រមទាំងឯកសារ សក្ខីប័ត្រពាក់ព័ន្ធ និង កត់ត្រារាល់ប្រតិបត្តិការ ។ បេឡាករបុរេប្រទានបំពេញភារកិច្ច ក្រោមការត្រួតពិនិត្យរួមគ្នា របស់មេឃុំ ចៅសង្កាត់ និងគណនេយ្យករឃុំ សង្កាត់ ។

មាត្រា ៣២.-

ការទទួលខុសត្រូវក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធអាចនឹងប្រគល់អោយមន្ត្រីម្នាក់ របស់រដ្ឋបាល ឃុំ សង្កាត់ ធ្វើជាភ្នាក់ងារប្រមូលចំណូល ។

ភ្នាក់ងារប្រមូលចំណូលត្រូវបានតែងតាំងឡើង និង បំពេញភារៈកិច្ចមានលក្ខណៈដូចគ្នា នឹងបេឡាករបុរេប្រទានដែរ ។

មាត្រា ៣៣.-

មេឃុំ ចៅសង្កាត់ត្រូវធានាថាប្រព័ន្ធគណនេយ្យថវិកាត្រូវបានអនុវត្ត ។

ប្រព័ន្ធគណនេយ្យថវិកាត្រូវបញ្ជីកា ការសន្យាចំណាយ និង ការអនុញ្ញាតអោយចំណាយដោយមេឃុំ ចៅសង្កាត់សំរាប់គោលបំណងនៃការតាមដានកិច្ចប្រតិបត្តិការថវិកា ។

## ជំពូកទី ៤

## របាយការណ៍ហិរញ្ញវត្ថុ

**មាត្រា ៣៤.-**

របាយការណ៍ហិរញ្ញវត្ថុត្រូវបំពេញនូវគោលបំណងដូចខាងក្រោម:

១- តាមដានកិច្ចប្រតិបត្តិការចំណូលនិងចំណាយរបស់ឃុំ សង្កាត់ ដោយប្រៀបធៀបជាមួយនឹងការព្យាករណ៍ថវិកា

២- វាយតំលៃស្ថានភាពហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ ដោយផ្តល់នូវព័ត៌មានអំពីប្រភព និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ

៣- បង្ហាញភាពគណនេយ្យ: ដល់មេឃុំ ចៅសង្កាត់ក្នុងការទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់លើ

៤- ឆ្លុះបញ្ចាំងអោយឃើញថាកិច្ចប្រតិបត្តិការឆ្លើយតបបានទៅនឹងថវិកាដែលបានអនុម័តនិងបទប្បញ្ញត្តិ គតិយុត្តផ្សេងទៀត ។

**មាត្រា ៣៥.-**

ឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍ដូចខាងក្រោម:

១- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកាប្រចាំខែ : របាយការណ៍នេះត្រូវមានទំរង់ជារបាយការណ៍ចំណូល ចំណាយផ្អែកតាមមាតិកាថវិកា។ ត្រូវប្រៀបធៀបការអនុវត្តន៍ជាក់ស្តែងទៅនឹងការព្យាករណ៍ថវិកា និងបង្ហាញអំពីស្ថានភាពរតនៈវត្ថុរបស់ឃុំ សង្កាត់

២- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកាប្រចាំឆមាស ដែលមានទំរង់ដូចគ្នាទៅនឹងរបាយការណ៍ប្រចាំខែ ដែរ

៣- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរួមមាន:

- របាយការណ៍ស្តីពីចំណូល ចំណាយប្រចាំឆ្នាំ
- ការផ្ទៀងផ្ទាត់គណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នៅរតនាគារ
- របាយការណ៍ស្តីពីអចលនវត្ថុ ។

របាយការណ៍ហិរញ្ញវត្ថុត្រូវមានភាពជាក់ស្តែងនិងប្រាកដប្រជា ទាក់ទងទៅ នឹងល័ក្ខខ័ណ្ឌទាំងឡាយ នៃការអនុវត្តន៍ថវិកាព្រមទាំងស្ថានភាពហិរញ្ញវត្ថុដំណាច់ឆ្នាំរបស់ឃុំ សង្កាត់ ។

**មាត្រា ៣៦.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវភ្ជាប់ជាមួយនូវរបាយការណ៍លំអិត ស្តីពីសកម្មភាពរបស់ឃុំ សង្កាត់។ របាយការណ៍សកម្មភាពប្រចាំឆ្នាំត្រូវពិពណ៌នា និងវាយតំលៃ:

- ការអនុវត្តន៍ការងាររបស់ឃុំ សង្កាត់ ក្នុងការប្រមូលចំណូល និងចំណាយ
- សមិទ្ធិផលរបស់ឃុំ សង្កាត់ក្នុងការផ្តល់សេវាសាធារណៈ ប្រៀបធៀបជាមួយនឹងទិសដៅ ផែនការ
- ស្ថានភាពសេដ្ឋកិច្ចរបស់ឃុំ សង្កាត់ និងផលប៉ះពាល់ពីប្រតិបត្តិការរបស់ឃុំ សង្កាត់ លើសុខមាលភាពរបស់ប្រជាជន ។

របាយការណ៍សកម្មភាព ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ ។

របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាព ជាឯកសារជំនួយក្នុងការបិទបញ្ជីគណនីឃុំ សង្កាត់ តាមការកំណត់ ។

**មាត្រា ៣៧.-**

របាយការណ៍ហិរញ្ញវត្ថុត្រូវរៀបចំឡើងដោយគណនេយ្យកររបស់ឃុំ សង្កាត់ និងត្រូវផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍គណនេយ្យថវិកា ដែលគ្រប់គ្រងដោយរដ្ឋបាលឃុំ សង្កាត់ ស្របទៅតាមប្រតិទិន ដូចខាងក្រោម:

- អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់សំរាប់របាយការណ៍ប្រចាំខែ
- អោយបានមុនថ្ងៃទី ២១ ខែកក្កដា សំរាប់របាយការណ៍ឆមាស
- អោយបានមុនថ្ងៃទី ៣១ ខែមករា នៃឆ្នាំបន្ទាប់សំរាប់របាយការណ៍ប្រចាំឆ្នាំ ។

**មាត្រា ៣៨.-**

មេឃុំ ចៅសង្កាត់ត្រូវពិនិត្យនិងឯកភាពទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយគណនេយ្យករ និងត្រូវផ្ញើជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិភាក្សា និងអនុម័តទាន់ពេលវេលា ដោយភ្ជាប់នូវរបាយការណ៍លំអិតអំពីសកម្មភាព ។

ក្រោយពីក្រុមប្រឹក្សាឃុំ សង្កាត់បានពិភាក្សា អនុម័តរួចមេឃុំ ចៅសង្កាត់ត្រូវ:

១- ផ្ញើរបាយការណ៍ជូនអភិបាលខេត្ត ក្រុង និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២- ផ្សព្វផ្សាយជាសាធារណៈ ។

## ជំពូកទី ៥
## ការគ្រប់គ្រងចំណាយ
### ផ្នែកទី ១
### ខួបនៃការចំណាយ

**មាត្រា ៣៩.-**

ចំណាយត្រូវសមស្របទៅនឹងថវិការបស់ឃុំ សង្កាត់និងសមស្របតាមច្បាប់ និង បទបញ្ញាទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា ។

ដំណើរការនៃចំណាយរបស់ឃុំ សង្កាត់ រួមមានដំណាក់កាលទាំងឡាយដូចខាងក្រោម:

១- ការសន្យា

២- កិច្ចជំរះបញ្ជី

៣- អាណត្តិកិច្ច

៤- ការទូទាត់ ។

8

**មាត្រា ៤០.-**

ការសន្យាត្រូវមានកិច្ចសន្យាឬការព្រមព្រៀងក្នុងការទិញមានលក្ខណៈបន្ទាន់ ឬ ការផ្គត់ផ្គង់សំភារៈ និងសេវាកម្ម នៅពេលខាងមុខ ។ ការសន្យាគឺជាការបញ្ជាក់នូវកាតព្វកិច្ចរបស់ឃុំ សង្កាត់ដែលត្រូវទូទាត់ ប្រសិនបើ អ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការបានបំពេញគ្រប់លក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ។

មុនពេលសន្យាលើចំណាយណាមួយ មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវធានាថា:

១- ចំណាយដែលបានស្នើពិតជាត្រឹមត្រូវទៅតាមប្រភេទថវិកា

២- មាននៅក្នុងឥណទានថវិកាព្រមទាំងមានមូលនិធិទំនេរគ្រប់គ្រាន់ និង ត្រឹមត្រូវតាមមាតិកាថវិកា

៣- នីតិវិធីលទ្ធកម្មនឹងអនុវត្តបានត្រឹមត្រូវ

៤- ការសន្យាចំណាយត្រូវបានកត់ត្រាដូចដែលបានបញ្ជាក់ក្នុងមាត្រា ៣៣នៃអនុក្រឹត្យនេះ

ការសន្យាចំណាយមិនត្រូវស្ថិតជាកម្មវត្ថុនៃការត្រួតពិនិត្យជាមុនរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង អាជ្ញាធរខេត្ត ក្រុងទេ ។

**មាត្រា ៤១.-**

ក្នុងកិច្ចជំរះបញ្ជី មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវធានាថា:

១- សំភារៈទាំងឡាយត្រូវបានប្រគល់ ឬសេវាត្រូវបានផ្តល់ដូចដែលបានបញ្ជាក់ត្រឹមត្រូវតាមកិច្ចសន្យា ឬការបញ្ជាទិញដែលបានព្រមព្រៀង

២- វិក័យប័ត្រដែលដាក់ជូនដោយអ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ត្រូវតែត្រឹមត្រូវទៅនឹងចំនួន និង ការងារអនុវត្តបាន ។

**មាត្រា ៤២.-**

បន្ទាប់ពីបញ្ចប់កិច្ចជំរះបញ្ជី មេឃុំ ចៅសង្កាត់ត្រូវចេញអាណត្តិបើកប្រាក់ ។

មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនអាណត្តិបើកប្រាក់រួមជាមួយឯកសារពាក់ព័ន្ធអោយគណនេយ្យករឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង ហើយទន្ទឹមនឹងនេះ ជូនដំណឹងដល់អ្នកត្រូវទទួលប្រាក់ ។

ក្នុងករណី ចំនួនទឹកប្រាក់ចំណាយស្ថិតនៅក្នុងកំរិតកំណត់ ដែលបានអនុញ្ញាតអោយប្រើប្រាស់បេឡាបុរេប្រទាន ការទូទាត់ត្រូវអនុវត្តតាមនីតិវិធីចំណាយនៃបេឡាបុរេប្រទានរបស់ឃុំ សង្កាត់ ។

**មាត្រា ៤៣.-**

គណនេយ្យករត្រូវធ្វើការទូទាត់ដល់អ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់ ឬក៏អ្នកទទួលសិទ្ធិដែលបានបញ្ជាក់ក្នុងអាណត្តិបើកប្រាក់ ។

មុនពេលទូទាត់ គណនេយ្យករត្រូវធ្វើការត្រួតពិនិត្យ និងបញ្ជាក់លើចំណុចដូចខាងក្រោម:

១- អាណត្តិបើកប្រាក់ត្រូវបានចុះហត្ថលេខាដោយអាណាប័កដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ

២- មន្ត្រីមុខការបានបញ្ជាក់ថា សំភារៈត្រូវបានទទួល ឬសេវាត្រូវបានផ្តល់ត្រឹមត្រូវតាមការព្រមព្រៀង

៣- វិក័យប័ត្រ និងឯកសារទាំងឡាយដែលជាសំណូមពរនៃការទូទាត់ពិតជាត្រឹមត្រូវ

៤- ឥណទាយកពិតជាត្រឹមត្រូវតាមកិច្ចសន្យា

៥- សំណើទូទាត់ពិតជាត្រឹមត្រូវតាមប្រភេទចំណាយ ព្រមទាំងមានថវិកាទំនេរគ្រប់គ្រាន់ក្នុងប្រភេទ ចំណាយនេះ

៦- ស្ថានភាពគណនីប្រាក់បញ្ញើឃុំ សង្កាត់ មានលទ្ធភាពទូទាត់បាន

៧- ការទូទាត់ត្រូវមានលក្ខណៈជាការរំដោះបំណុល ។

ក្នុងករណីមិនបានបំពេញល័ក្ខខ័ណ្ឌខាងលើគ្រប់គ្រាន់ គណនេយ្យករមានសិទ្ធិផ្អាកការទូទាត់ ហើយជូនដំណឹងជាបន្ទាន់ដល់មេឃុំ ចៅសង្កាត់ដោយបញ្ជាក់អំពីមូលហេតុ និង សំណូមពរបំពេញបន្ថែម ។

**មាត្រា ៤៤.-**

ក្នុងករណីមានបញ្ហាក្នុងការទូទាត់ មេឃុំ ចៅសង្កាត់ និង គណនេយ្យករត្រូវពិភាក្សាដើម្បីរកដំណោះស្រាយស្រប តាមនីតិវិធីនៃការទូទាត់ ។

ប្រសិនបើការពិភាក្សាមិនបានឯកភាពគ្នាទេ មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនសំណុំរឿងនេះទៅអភិបាលខេត្ត ក្រុងជួយដោះស្រាយ ។ សេចក្តីសំរេចរបស់អភិបាលខេត្ត ក្រុងចាត់ទុកជាការសំរេចចុងក្រោយចំពោះទំនាស់នេះ និងត្រូវភ្ជាប់ជាឯកសារបន្ថែមនៃការទូទាត់ ។

## ផ្នែកទី២

## ការទិញលទ្ធកម្មសាធារណៈ

**មាត្រា ៤៥.-**

លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សំភារៈ និង ការផ្តល់សេវាត្រូវតែស្របទៅតាមគោលការណ៍ទូទៅដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ។

**មាត្រា ៤៦.-**

មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការលទ្ធកម្មមួយទទួលបន្ទុកការងារទាំងឡាយរួមមានៈ

១ -ធ្វើការវាយតំលៃលើការដេញថ្លៃរបស់អ្នកម៉ៅការ និង អ្នកផ្គត់ផ្គង់

២-ផ្តល់អនុសាសន៍ លើការសំរេចចុះកិច្ចសន្យា ។

គណៈកម្មការលទ្ធកម្មត្រូវធានាថាៈ

- លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សំភារៈ និងការផ្តល់សេវា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព និង សន្សំសំចៃ

- អ្នកម៉ៅការ និង អ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នាក្នុងការចូលរួមប្រកួតប្រជែងផ្គត់ផ្គង់សំភារៈ និងផ្តល់សេវាក្រោមល័ក្ខខ័ណ្ឌតែមួយ
- លទ្ធផលនៃការងារលទ្ធកម្មត្រូវប្រកាសជាសាធារណៈ

**មាត្រា ៤៧.-**

គណៈកម្មការលទ្ធកម្មត្រូវមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| - មេឃុំ ចៅសង្កាត់ ឬ អ្នកទទួលសិទ្ធិ | ប្រធាន |
| - សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពីររូប | សមាជិក |
| - ស្មៀនឃុំ សង្កាត់ | លេខាធិការ |

ប្រធានគណៈកម្មការលទ្ធកម្មអាចអញ្ជើញបុគ្គលមួយចំនួនចូលរួមជាអ្នកជំនួយការ ឬជាអ្នកសង្កេតការណ៍។ ក្នុងការប្រជុំពិភាក្សាការងារ របស់ គណៈកម្មការលទ្ធកម្ម អ្នកជំនួយការ លេខាធិការ និងអ្នកសង្កេតការណ៍ ពុំមានសិទ្ធិសំរេចទេ។ គណៈកម្មការលទ្ធកម្ម ត្រូវធ្វើសេចក្តីសំរេចដោយសំលេងភាគច្រើន ។

ក្នុងករណីមានសំលេងស្មើគ្នានោះ សំលេងរបស់ប្រធានចាត់ទុកជាសំលេងឧត្តមភាព ។

**មាត្រា ៤៨.-**

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំ របស់គណៈកម្មការលទ្ធកម្ម មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសំរេចចុងក្រោយស្តីពីការប្រគល់កិច្ចសន្យា។

## ជំពូកទី ៦
## ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់

**មាត្រា ៤៩.-**

ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់រួមមានបីប្រភេទៈ

១-ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលផ្ទេរសិទ្ធិអោយកាន់កាប់

២-ទ្រព្យសម្បត្តិដែលឃុំ សង្កាត់ទិញដោយខ្លួនឯង

៣-ទ្រព្យសម្បត្តិដែលបានមកពីអំណោយនានា។

**មាត្រា ៥០.-**

ឃុំ សង្កាត់ត្រូវរក្សាការកត់ត្រាដោយឡែកប្រភេទទ្រព្យសម្បត្តិទាំងបីខាងលើ តាមប្រភេទនីមួយៗ នូវពត៌មានដូចខាងក្រោមៈ

១- លេខរៀង ឬលេខកូដ

២- យថាប្រភេទ

៣- កាលបរិច្ឆេទផ្ទេរសិទ្ធិអោយកាន់កាប់

៤- បរិមាណ និង តំលៃ

៥- ទីតាំងដែលទ្រព្យសម្បត្តិនោះទុកដាក់ ឬប្រើប្រាស់

មេឃុំ ចៅសង្កាត់ត្រូវធានាកត់ត្រាក្នុងបញ្ជីទ្រព្យសម្បត្តិអោយបានត្រឹមត្រូវ ។

**មាត្រា ៥១.-**

ចលនៈវត្ថុនានាត្រូវមានលេខកូដសំគាល់ដើម្បីងាយស្រួលដឹងថានៅទីកន្លែងណា និង អាចជួយដល់ការ កត់ត្រាបញ្ជីចលនៈវត្ថុ ។

មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការមួយធ្វើសារពើភណ្ឌ អោយបានយ៉ាងតិច១ដងក្នុង១ឆ្នាំ ចំពោះអចលនៈវត្ថុរបស់ខ្លួន ដើម្បីដឹងបានចំនួនបាត់បង់ ហើយធ្វើការកែតម្រូវបញ្ជី ព្រមទាំងវាយតំលៃចំពោះស្ថានភាពរបស់ទ្រព្យសម្បត្តិដើម្បីរៀប ចំជួសជុល ថែទាំ ឬជំនួសថ្មី ។

លទ្ធផលនៃសារពើភ័ណ្ឌ ត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយបញ្ជីអចលនៈវត្ថុ បើឃើញមានការខុសគ្នា ត្រូវតែធ្វើការអង្កេតបញ្ជាក់មូលហេតុច្បាស់លាស់ និងកែតម្រូវបញ្ជី អចលនៈវត្ថុទៅតាមនោះ ។

តារាងសង្ខេប ព្រមទាំងរបាយការណ៍សារពើភ័ណ្ឌអចលនៈវត្ថុ ចាំបាច់ត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។

**មាត្រា ៥២.-**

អនុលោមតាមមាត្រា៨១ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរ ឬ ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលប្រគល់អោយ ដោយគ្មានការយល់ព្រមជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ ឯកភាពរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ ។

**មាត្រា ៥៣.-**

ឃុំ សង្កាត់មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលបានទិញដោយចំណូលផ្ទាល់របស់ខ្លួន ។

ការលក់ដូរ ឬ ការផ្ទេរកម្មសិទ្ធិ ឬការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម:

១- មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មការចំពោះកិច្ចមួយ ដើម្បីត្រួតពិនិត្យលើការលក់ដូរឬផ្ទេរទ្រព្យសម្បត្តិ។ គណៈកម្មការនេះត្រូវដឹកនាំដោយមេឃុំ ចៅសង្កាត់ និងមានសមាជិកក្រុមប្រឹក្សាមួយរូប និងបុគ្គលម្នាក់ទៀតជាគណនេយ្យករឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង។ ស្មៀនឃុំ សង្កាត់ត្រូវធ្វើជាលេខាធិការ ។

២- ដំណើរការលក់ដូរ ឬផ្ទេរត្រូវធានាអោយមានតម្លាភាព និងបើកទូលាយដល់ការប្រកួតប្រជែងយ៉ាងពិតប្រាកដ

៣-ក្នុងការលក់ដូរ ឬផ្ទេរ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសំរេច ផ្អែកតាមអនុសាសន៍របស់គណៈកម្មការចំពោះកិច្ច

8

៤- ចំនួនទឹកប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិត្រូវរក្សាទុកក្នុងគណនីរបស់ឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង ។

**មាត្រា ៥៤.-**

ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ដែលបានមកពី អំណោយត្រូវគោរពទៅតាមល័ក្ខខ័ណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់អំណោយនិងឃុំ សង្កាត់ ។

ក្នុងករណីអំណោយគ្មានល័ក្ខខ័ណ្ឌពីម្ចាស់អំណោយ ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា ៥៣នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៧

## សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ សង្កាត់

**មាត្រា ៥៥.-**

មេឃុំ ចៅសង្កាត់ត្រូវធានាថាយន្តការត្រួតពិនិត្យផ្ទៃក្នុងដែលមានក្នុងប្រព័ន្ធគ្រប់គ្រង ត្រូវបានអនុវត្តដើម្បីសំរេចអោយបានតាមគោលដៅដូចខាងក្រោម:

- ធនធានត្រូវបានប្រើប្រាស់ស្របតាមថវិកាដែលបានអនុម័តព្រមទាំងស្របតាម ច្បាប់ និង បទបញ្ញាជាធរមាន
- ធនធានត្រូវបានទុកដាក់គត់មត់ មិនបាត់បង់ និងមិនប្រើប្រាស់ខុសគោលការណ៍
- ទិន្នន័យហិរញ្ញវត្ថុពិតប្រាកដត្រូវបានរៀបចំ និង លាតត្រដាងក្នុងរបាយការណ៍ ។

**មាត្រា ៥៦.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ជាកម្មវត្ថុសំរាប់សវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ច ។

គោលបំណងនៃសវនកម្មគឺសំដៅធានាភាពជាក់លាក់ ត្រឹមត្រូវនៃពត៌មានហិរញ្ញវត្ថុ វាយតំលៃការអនុវត្តន៍ថវិការបស់ឃុំ សង្កាត់ ប្រព័ន្ធគ្រប់គ្រង និង នីតិវិធី ។ របាយការណ៍សវនកម្មដែលមានរួមបញ្ចូលនូវមតិយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥៧.-**

គណនី និង ប្រតិបត្តិការរបស់ឃុំ សង្កាត់អាចត្រូវធ្វើសវនកម្មដោយស្ថាប័នជាតិ ឬដោយសវនកររឯករាជ្យមិនមែនរដ្ឋាភិបាល តាមសំណូមពររបស់ម្ចាស់ជំនួយក្រៅប្រទេស ដែលផ្តល់ហិរញ្ញប្បទានដល់ឃុំ សង្កាត់ ។

**មាត្រា ៥៨.-**

អភិបាលខេត្ត ក្រុងត្រូវធានាថាសវនកម្មដែលមានលក្ខណៈជាការពិគ្រោះយោបល់ ធ្វើឡើងតាមស្មារតីភាព ជំនួយបច្ចេកទេស និងមានលក្ខណៈជាការកសាងសមត្ថភាពខាងការគ្រប់គ្រង ហិរញ្ញវត្ថុ និង កិច្ចប្រតិបត្តិការ ត្រូវបានផ្តល់អោយឃុំ

ដល់ឃុំ សង្កាត់ទៀងទាត់ជាប្រចាំ ។

មាត្រា ៥៩.-

ប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការពិនិត្យ តាមដានការអនុវត្តន៍របស់ ក្រុមប្រឹក្សា និង រដ្ឋបាលឃុំ សង្កាត់ ។ មេឃុំ ចៅសង្កាត់ត្រូវធានាថា:

១- រាល់ព័ត៌មានស្តីពីសកម្មភាព និងគណនីរបស់ឃុំ សង្កាត់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ

២- ការទទួលមតិសាធារណៈនិងការពិគ្រោះយោបល់ត្រូវបានប្រព្រឹត្តទៅក្នុងដំណើរការរៀបចំថវិកា

៣- ប្រជាពលរដ្ឋត្រូវបានទទួលការលើកទឹកចិត្ត និង អញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

មាត្រា ៦០.-

មេឃុំ ចៅសង្កាត់ ក្នុងឋានៈជាអាណាប័ក គណនេយ្យករឃុំ សង្កាត់ និងបុគ្គលទាំងឡាយដែលចូលរួមនៅក្នុងដំណើរការអនុវត្តន៍ថវិកាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់សកម្មភាពរំលោភទៅលើវិន័យថវិកា ដូចខាងក្រោម:

១- ការសន្យាចំណាយ លើសឥណទានថវិកាដែលបានទទួលការអនុញ្ញាត

២- រាល់អំពើដែលជាកម្មវត្ថុសំរាប់បង្កើនទឹកប្រាក់ឥណទានថវិកាដែលបានទទួលការអនុញ្ញាតដោយធនធានពិសេសក្រៅពីករណីដែលបានកំណត់ដោយច្បាប់និងបទបញ្ជាជាធរមាន

៣- រាល់កំហុសធ្ងន់ធ្ងរដែលនាំអោយមានការខាតបង់ប្រាក់កាសដល់ហិរញ្ញវត្ថុ ឬទ្រព្យសម្បត្តិ របស់ឃុំ សង្កាត់ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

មាត្រា ៦១.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំស្តីពីការអនុវត្តន៍ជាក់ស្តែង រាល់កិច្ចការទាំងឡាយ ដូចមានចែងនៅក្នុងជំពូកទី២ ដល់ជំពូកទី៧ នៃអនុក្រឹត្យនេះ ។

មាត្រា ៦២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី

ស ខេង យូ ហុកគ្រី គាត ឈន់

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*កន្លែងទទួល*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៥.០០០ លានរៀល ( ប្រាំពាន់លានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១៧...អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតវិទ្យាស្ថានក្រុងអង្គរ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការ ប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការ គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញលិខិតស្នើសុំរបស់ លោក ហុក សឿន ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០១
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

**សំរេច**

**មាត្រា ១ :** អនុញ្ញាតអោយបង្កើត គ្រឹះស្ថានឧត្តមសិក្សា ឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានក្រុងអង្គរ** (Angkor City Institute) ហៅកាត់ជាភាសាខ្មែរ "វកអ" និងហៅកាត់ជាភាសាអង់គ្លេស "ACI" ។

វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំង នៅអាគារ លេខ ២៣២ ភូមិវិហារចិន ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

**មាត្រា ២ :** វិទ្យាស្ថានក្រុងអង្គរ ធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សាយ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ៣២០០ ម៉ោង ជាមធ្យម ។

**មាត្រា ៣ :** វិទ្យាស្ថានក្រុងអង្គរ មានមហាវិទ្យាល័យ :

- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍
- មហាវិទ្យាល័យ នីតិសាស្ត្រ និង សេដ្ឋកិច្ច
- មហាវិទ្យាល័យពតិមានវិទ្យា

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេសជំនាញ ដ៏ទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានក្រុងអង្គរ មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារ ពិនិត្យ និង សំរេច លើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់វិទ្យាស្ថាន និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយសំរាប់ ពិនិត្យលើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** នាយកវិទ្យាស្ថានក្រុងអង្គរ មានភារកិច្ច :

- ជ្រើសរើសនិស្សិតអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវ ការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៦ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានក្រុងអង្គរ និង បានទទួលជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់អោយ ដោយវិទ្យាស្ថានក្រុងអង្គរ ហើយ ត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថាននេះបានបំពេញ និង អនុវត្ត តាមគោលការណ៍ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានក្រុងអង្គរ មានភារកិច្ចរៀង ៗ ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាម អនុក្រឹត្យនេះ ។

**មាត្រា ៨ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ភ្នំពេញ ថ្ងៃទី០៨ ខែ មេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាខេត្តសៀមរាប

  " ដើម្បីមុខការ "
- ដូចមាត្រា ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៧ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយការងារ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនដល់ឯកឧត្តម អស់លោកថ្នាក់ដឹកនាំខេត្ត ក្រុង ចំនួន ០៣រូប ដែលមានស្នាដៃឆ្នើមក្នុងការអភិវឌ្ឍន៍ខេត្តកោះកុងកន្លងមកដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **សាយ ហាក់** អភិបាល ក្រុងព្រះសីហនុ
២-លោក **ជាម ហ៊ឹម** អភិបាលរងទី២ ខេត្តកោះកុង
៣-លោក **ពេជ ហាន** អភិបាលរងទី៣ ខេត្តកោះកុង

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និង មាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមស្តីពីលក្ខន្តិកៈ ទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតរាជាយស្វ័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **សុខុម គគចន្ទមុនី** ជាប្រធានអគ្គនាយក នៃសហគ្រាសសាធារណៈរាជាយស្វ័យយានកម្ពុជា ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ_កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៣ រូប ដែលបានធ្វើអំណោយសំរាប់ការចិញ្ចឹម និង បណ្តុះបណ្តាលកុមារកំព្រានៅក្រុងកែប រួមមានការកសាង អាគារសិក្សា ០២ ខ្នង គ្រែដេក សំលៀកបំពាក់ និង សំភារៈសិក្សា សរុបអស់ទឹកប្រាក់ចំនួន ៣៧.១០០ ដុល្លារអាមេរិក ដូចមាននាមខាងក្រោម ÷

១-លោកស្រី **ហួន សារី** ប្រធានអង្គការ

២-លោក **ចៅង យ៉ាំវ៉ាន់** អនុប្រធានអង្គការ

៣-លោក **HENRY CHRISTIAN KELLE** នាយកកម្មវិធី

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ១១ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...១៥៩...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានកាកបាទក្រហមកម្ពុជា

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកស្រី Seija Tyrninoksa ប្រធានប្រតិភូសហព័ន្ធអន្តរជាតិកាកបាទក្រហម អឌ្ឍច័ន្ទក្រហម ប្រចាំកម្ពុជា ដែលបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយកាកបាទក្រហមកម្ពុជា ក្នុងការទាក់ទាញរកជំនួយឧបត្ថម្ភពីសមាគមជាតិនៃ បណ្តាប្រទេសនានា ក្នុងតំបន់ និង ក្នុងពិភពលោក ព្រមទាំងជួយអភិវឌ្ឍកាកបាទក្រហមកម្ពុជាអោយមានកេរ្តិ៍ឈ្មោះល្បីរន្ទឺ ក្នុងចលនាអន្តរជាតិកាកបាទក្រហម អឌ្ឍច័ន្ទក្រហម ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានកាកបាទក្រហមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **សុខ អឿន** ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ស្តារ និង ថែរក្សាវប្បធម៌ជាតិ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៧១ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ០៦ រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តបាក់ដាវ ឃុំបាក់ដាវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមាននាមខាងក្រោម ÷

**ក_មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ខឹម** | **សារ៉ន** | ចៅអធិការវត្ត | បច្ច័យ ៥៧.៦៤៨ USD |
| ២-លោក | **ទើង** | **ហួ** | មេឃុំបាក់ដាវ | ថវិកា ៥៧.៦៤៨ USD |
| ៣-លោក | **លឹម** | **ទ៉ិនសួ** | សប្បុរសជន | ថវិកា ១៣.០០០ USD |
| ៤-លោក | **ឱ្យ** | **រស់** | សប្បុរសជន | ថវិកា ១០.១៥៥ USD |
| ៥-លោក | **ជាវ** | **ញ៉ឹប** | សប្បុរសជន | ថវិកា ១០.៥៩៩ USD |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ស៊ីវ** **ឡេង** ថវិកា ៥.២៥០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៦២...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១ ៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/ ០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ .

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនដល់មន្ត្រីរាជការក្នុងក្រុងភ្នំពេញ ចំនួន ១៧ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច កន្លងមក ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- | លោក សុខ ស៊ុយ | នាយរងខុទ្ទកាល័យ | សាលាក្រុង |
| ២- | លោក ទូច វណ្ណារិទ្ធ | នាយការិយាល័យរដ្ឋបាល | សាលាក្រុង |
| ៣- | លោក ឌិម សំអឿល | ជំនួយការឯកឧត្តមប្រតិភូ | សាលាក្រុង |
| ៤- | លោក គីម សារុធ | នាយការិយាល័យសរុប | សាលាក្រុង |
| ៥- | លោក ប៊ុន សេរី | នាយការិយាល័យគណនេយ្យ | សាលាក្រុង |
| ៦- | លោក ណាក តាណារុឌ | នាយការិយាល័យអន្តរជាតិ | សាលាក្រុង |
| ៧- | លោក មួង សារី | ប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |

| | | | |
|---|---|---|---|
| ៨- | លោក **ឯក ធានី** | **មន្ត្រីសាលាខ័ណ្ឌ** | **សាលាខ័ណ្ឌ៧មករា** |
| ៩- | លោក **អេង ខួន** | **អភិបាលរងខ័ណ្ឌ** | **សាលាខ័ណ្ឌដូនពេញ** |
| ១០- | លោក **សុខ សម្បត្តិ** | **អភិបាលរងខ័ណ្ឌ** | **សាលាខ័ណ្ឌដូនពេញ** |
| ១១- | លោក **ហែម អាន** | **ប្រធានមន្ទីរខ័ណ្ឌ** | **សាលាខ័ណ្ឌដូនពេញ** |
| ១២- | លោក **ជ័យ សាឡុង** | **អភិបាលខ័ណ្ឌ** | **សាលាខ័ណ្ឌចំការមន** |
| ១៣- | លោក **គួច ចំរើន** | **អភិបាលរងខ័ណ្ឌ** | **សាលាខ័ណ្ឌចំការមន** |
| ១៤- | លោក **គឹម ឈុនអ៊ី** | **អភិបាលរងខ័ណ្ឌ** | **សាលាខ័ណ្ឌចំការមន** |
| ១៥- | លោក **ឡូច សារុន** | **អភិបាលខ័ណ្ឌ** | **សាលាខ័ណ្ឌឫស្សីកែវ** |
| ១៦- | លោក **ម៉ៃ ម៉ុន** | **អភិបាលរងខ័ណ្ឌ** | **សាលាខ័ណ្ឌដង្កោ** |
| ១៧- | លោក **សាន ស៊ីថាន់** | **ប្រធានមន្ទីរខ័ណ្ឌ** | **សាលាខ័ណ្ឌដង្កោ** |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។/.

*រាជធានីភ្នំពេញ .ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

*- ក្រសួងព្រះបរមរាជវាំង*
*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*- ដូចក្នុងមាត្រា១ និងមាត្រា២*
*- រាជកិច្ច* ✓
*- ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/ ០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ .

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយប្រាក់ការងារ** ជូនដល់មន្ត្រីរាជការក្នុងក្រុងភ្នំពេញ ចំនួន ៣២ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម :

១- លោក **ខៀវ សុខុម** **នាយរងខុទ្ទកាល័យ** **សាលាក្រុង**
២- លោកស្រី **គីម វឌ្ឍនធីតា** **នាយរងខុទ្ទកាល័យ** **សាលាក្រុង**
៣- លោក **សួរ ដាន់ណារ៉ា** **នាយរងការិយាល័យរដ្ឋបាល** **សាលាក្រុង**
៤- លោក **ឆេង ច័ន្ទវត្ថា** **នាយរងការិយាល័យសរុប** **សាលាក្រុង**
៥- លោក **អ៊ុក សុផល** **នាយរងការិយាល័យគណនេយ្យ** **សាលាក្រុង**
៦- លោក **ម៉ៃ សោរី** **មន្ត្រីការិយាល័យវិនិយោគ** **សាលាក្រុង**
៧- លោកស្រី **ឈឹម ធូនី** **នាយរងការិយាល័យពិធីការ** **សាលាក្រុង**
៨- លោក **អ៊ុក យាង** **នាយការិយាល័យអន្តរានុកូលដ្ឋាន** **សាលាក្រុង**

| | | |
|---|---|---|
| ៩- លោក ឃុន ម៉ុន្ន | មន្ត្រីការិយាល័យរដ្ឋបាល | សាលាក្រុង |
| ១០- លោក ចាន់ សុភមៀន | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |
| ១១- លោក សុខ អាត | នាយការិយាល័យសេដ្ឋកិច្ចខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |
| ១២- លោក ឌួង គីមយ៉ាន | អនុប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌដូនពេញ |
| ១៣- លោក សុខ ពេញវុធ | នាយការិយាល័យរដ្ឋបាលទូទៅ | សាលាក្រុង |
| ១៤- លោក ស៊ាម ឈន់ | នាយរងការិយាល័យរដ្ឋបាលទូទៅ | សាលាក្រុង |
| ១៥- លោក នាង សុផារី | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌដូនពេញ |
| ១៦- លោក នន្ទ សំអូន | ប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ១៧- លោកស្រី សួន ចាន់ណារី | នាយការិយាល័យរដ្ឋបាលទូទៅខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ១៨- លោក ឯក យឿន | នាយការិយាល័យសង្គមកិច្ចខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ១៩- លោក សោម សុឃុន | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ២០- លោក ផែង សុខេម | ប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ២១- លោកស្រី ទួន នារី | នាយការិយាល័យសង្គមកិច្ចខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ២២- លោកស្រី កែប សំបូរ | នាយការិយាល័យរដ្ឋបាលទូទៅខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ២៣- លោក សៅ មឿន | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ២៤- លោក សារ មុយខៀង | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ២៥- លោក ប៉ាង សុធីរ | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ២៦- លោក ទូច គីមហេង | អភិបាលរងខ័ណ្ឌ | សាលាខ័ណ្ឌឫស្សីកែវ |
| ២៧- លោក យ៉ាវ ជឿន | ប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌឫស្សីកែវ |
| ២៨- លោកស្រី កែវ ចាន់ស៊ុនណារី | អនុប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌឫស្សីកែវ |
| ២៩- លោក គីម សារិន | អនុប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌដង្កោ |
| ៣០- លោក ខៀវ ឃីនាថ | នាយការិយាល័យរដ្ឋបាលទូទៅខ័ណ្ឌ | សាលាខ័ណ្ឌដង្កោ |
| ៣១- លោក ឃុន វណ្ណា | មន្ត្រីសាលាក្រុង | សាលាក្រុង |
| ៣២- លោក ចាន់ ពិសិដ្ឋ | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] (៤-៧) ឆ្នាំ២០០២*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៤ អនក្រ-តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១ ៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/ ០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ .

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍការងារ** ជូនដល់មន្ត្រីរាជការក្នុងក្រុងភ្នំពេញ ចំនួន ៤០ រូប ដែលមានស្នាដៃល្អក្នុងការ បំពេញភារកិច្ច កន្លងមក ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- | លោក សូរ សិទ្ធ | នាយរងការិយាល័យគណនេយ្យ | សាលាក្រុង |
| ២- | លោក ម៉ៅ សំរឿន | នាយរងការិ.ផ្សព្វផ្សាយពាណិជ្ជកម្ម | សាលាក្រុង |
| ៣- | លោកស្រី ម៉ក់ សុភាទី | មន្ត្រីការិយាល័យរដ្ឋបាល | សាលាក្រុង |
| ៤- | លោក ស្លួត សំម៉ុន | មន្ត្រីការិយាល័យសរុប | សាលាក្រុង |
| ៥- | លោក នាង ចេម | មន្ត្រីការិយាល័យសរុប | សាលាក្រុង |
| ៦- | លោក ឈាង ទ៊ាន | មន្ត្រីការិយាល័យសរុប | សាលាក្រុង |
| ៧- | លោក ចន្ទ័ តារាវុធ | នាយរងការិយាល័យគណនេយ្យ | សាលាក្រុង |

| | | | |
|---|---|---|---|
| ៨- | លោកស្រី ចាន់ ច្រិប | មន្ត្រីការិយាល័យរដ្ឋបាល | សាលាក្រុង |
| ៩- | លោក ខាម ហេង | មន្ត្រីសាលាក្រុង | សាលាក្រុង |
| ១០- | លោក ជុំ យន់ | នាយរងការិយាល័យបុគ្គលិក | សាលាក្រុង |
| ១១- | លោក យ៉ង់ សមកុល | អនុប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |
| ១២- | លោក ថៃ ដារ៉ា | នាយការិយាល័រដ្ឋបាលខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |
| ១៣- | លោក ម៉ុក សាន | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |
| ១៤- | លោកស្រី យឹម ថាវី | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |
| ១៥- | លោក លឹម ហ៊ិត | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌ៧មករា |
| ១៦- | លោក អ៊ំ រឿន | នាយការិយាល័យសេដ្ឋកិច្ចខ័ណ្ឌ | សាលាខ័ណ្ឌដូនពេញ |
| ១៧- | លោក មុត សារាខាំ | នាយរងការិយាល័យសង្គមកិច្ចខ័ណ្ឌ | សាលាខ័ណ្ឌដូនពេញ |
| ១៨- | លោក អ៊ុ សុជាតិ | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌដូនពេញ |
| ១៩- | លោក មាស មុនិន្ទ | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌដូនពេញ |
| ២០- | លោក យុត គីរី | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌដូនពេញ |
| ២១- | លោក ពៅ វណ្ណា | អនុប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ២២- | លោក តុង វុិត | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ២៣- | លោក ឈុន វណ្ណារិទ្ធ | នាយរងការិយាល័យសេដ្ឋកិច្ចខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ២៤- | លោក ទូច ចាន់ថន | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ២៥- | លោក ពេជ្រ មុនី | នាយរងការិយាល័យរដ្ឋបាលខ័ណ្ឌ | សាលាខ័ណ្ឌទួលគោក |
| ២៦- | លោក ហ៊ុន សារឿន | នាយរងការិយាល័យសេដ្ឋកិច្ច | សាលាខ័ណ្ឌចំការមន |
| ២៧- | លោក អ៊ុម វណ្ណារិទ្ធ | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ២៨- | លោក ចន្ទ័ សៅរ៍ | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ២៩- | លោក នុយ ប៊ុនសេរីរត្ន័មុនី | អនុប្រធានមន្ទីរខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ៣០- | លោក ថោង សុផាត | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌចំការមន |
| ៣១- | លោកស្រី ប៊ី ណៃ | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌមានជ័យ |
| ៣២- | លោក នួន សុមានិត | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌមានជ័យ |
| ៣៣- | លោក សាយ ប៊ុនធឿន | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌមានជ័យ |
| ៣៤- | លោក លឹម ស្រួយ | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌមានជ័យ |
| ៣៥- | លោក នង សាមុត | នាយការិការិយាល័យសេដ្ឋកិច្ចខ័ណ្ឌ | សាលាខ័ណ្ឌឫស្សីកែវ |
| ៣៦- | លោក ប្រាក់ ចាន់ណា | នាយការិយាល័យរដ្ឋបាលទូទៅខ័ណ្ឌ | សាលាខ័ណ្ឌឫស្សីកែវ |
| ៣៧- | លោក វ៉ាន សាលី | មន្ត្រីសាលាខ័ណ្ឌ | សាលាខ័ណ្ឌឫស្សីកែវ |
| ៣៨- | លោក សាយ ស្រេង | នាយរងការិយាល័យសេដ្ឋកិច្ចខ័ណ្ឌ | សាលាខ័ណ្ឌឫស្សីកែវ |

៣៩- លោក កៅ ចឿន មន្ត្រីសាលាខំណ្ឌ សាលាខណ្ឌដង្កោ

៤០- លោក អ៊ុក សារ៉េត មន្ត្រីសាលាខំណ្ឌ សាលាខណ្ឌដង្កោ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រធានអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព។ បន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៧៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី ចំនួន ៥៦ រូប បំរើការក្នុងខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជួយដល់ការងារដឹកនាំរាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១-លោក | **ប៊ុន** | **ខេង** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ២-លោក | **សេង** | **ឡៀង** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៣-លោក | **សោម** | **សុវុឌ្ឍី** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៤-លោក | **សុខ** | **សុរិយា** | ពិធីការសម្តេចនាយករដ្ឋមន្ត្រី |
| ៥-លោកស្រី | **រស់** | **ចំនួនផល្លី** | ពិធីការលោកជំទាវសម្តេចនាយករដ្ឋមន្ត្រី |
| ៦-លោកស្រី | **ថ្វី** | **សុខា** | ពិធីការទូទៅ |
| ៧-លោក | **សំ** | **វណ្ណារ៉ា** | មន្ត្រីក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី |
| ៨- លោក | **ហាក់** | **សុខហៃ** | មន្ត្រីក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី |
| ៩- លោក | **អៀង** | **សិរីវង្ស** | មន្ត្រីក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី |

| | | | |
|---|---|---|---|
| ១០- លោក | ជា | យុពា | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១១- លោក | ឃឹម | រស្មីដា | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១២- លោក | នុត | បុពិណ្ណារ៉ា | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១៣- លោក | អ៊ុក | ចន | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១៤- លោក | ឈួន | គឹមឆយ | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១៥- លោកស្រី | ម៉ាន់ | ចរិយា | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១៦- លោក | អ៊ឹង | ចេងស៊ុង | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១៧- លោក | ស្លាត | សុភាព | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១៨- លោក | ខៀវ | សានថា | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ១៩- លោក | ជាម | ផារី | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ២០- លោក | ឈឹម | សារ៉េត | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ២១- លោក | ឯក | ធីរៈវឌ្ឍ | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ២២- លោក | ម៉ុញ | បានកុសល | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ២៣- លោក | ឈរ | ផល្លី | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ២៤- កញ្ញា | ឈរ | ស្រីពីង | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ២៥- លោក | ជា | សារឿន | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ២៦- លោក | សុខ | ធីរៈ | មន្ត្រីក្រុមលេខាសម្ដេចនាយករដ្ឋមន្ត្រី |
| ២៧- លោក | ឈន | ម៉េងឡេង | មន្ត្រី ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី |
| ២៨- លោក | គឹម | ណាន | ជំនួយការឯកឧត្តម យូ ស៊ុនឡុង |
| ២៩- លោក | ខួន | ស្រេង | ជំនួយការឯកឧត្តម យូ ស៊ុនឡុង |
| ៣០- លោក | គាំ | សុខុន | ជំនួយការឯកឧត្តម យូ ស៊ុនឡុង |
| ៣១- លោក | ង៉ា | ហៀង | ជំនួយការឯកឧត្តម មល់ រឿប |
| ៣២- លោក | ឃូ | មនោ | ជំនួយការខុទ្ទកាល័យ |
| ៣៣- លោក | ហម | ជាតិ | ជំនួយការឯកឧត្តម អ៊ឹង ប៊ុណ្ណារ៉ា |
| ៣៤- លោក | ឯក | សុខន | ជំនួយការឯកឧត្តម ឃិន គឹមសាន |
| ៣៥- លោក | ថៅ | វឌ្ឍា | ជំនួយការឯកឧត្តម សម សុត្ថា |
| ៣៦- លោក | ជេត | សារ៉េត | ជំនួយការឯកឧត្តម គៀង សាវុធ |

៣៧- លោក ម៉ាង ណាសជាតិ ជំនួយការឯកឧត្តម គៀង សាវុធ

៣៨- លោក យ៉ុង សារិន ជំនួយការឯកឧត្តម គៀង សាវុធ

៣៩- លោក ព្រុំ ជុំវីណា ជំនួយការឯកឧត្តម គន់ គីម

៤០- លោក អ៊ិត សាមួន ជំនួយការឯកឧត្តម មល់ រឿប

**ខ_មេដាយប្រាក់ការងារ**

១-លោក មាស វិបុល ជំនួយការខុទ្ទកាល័យ

២-លោកស្រី ញៀម ស៊ីណាត ជំនួយការខុទ្ទកាល័យ

៣-កញ្ញា គង់ មារីយ៍ ជំនួយការខុទ្ទកាល័យ

៤-លោកស្រី សូ ដារ៉ា ជំនួយការខុទ្ទកាល័យ

៥-កញ្ញា មាស វិចិត្រា ជំនួយការខុទ្ទកាល័យ

៦-លោកស្រី ហែម យ៉ានី ជំនួយការខុទ្ទកាល័យ

៧-លោកស្រី ឆេង សុដារី ជំនួយការខុទ្ទកាល័យ

៨-លោក ឆេង ស៊ីថា ជំនួយការខុទ្ទកាល័យ

៩-លោក គោគ វ៉ាន់ថន អ្នកបើកបរ

១០-លោក នី ប៊ុនលី អ្នកបើកបរ

១១-លោក អ៊ុំ ម៉ារ៉ា ជំនួយការឯកឧត្តម គៀង សាវុធ

១២-លោក ម៉ាក សុដារី មន្ត្រីបច្ចេកទេសវិទ្យុ

១៣-លោក ទៅ ពេជ្រ មន្ត្រីបច្ចេកទេសវិទ្យុ

១៤-លោក គំរូ វណ្ណឌី មន្ត្រីបច្ចេកទេសវិទ្យុ

១៥-លោក រាល ម៉ារាទី មន្ត្រីបច្ចេកទេស AFP

១៦-លោក សោម ប៊ុណ្ណារ៉ា មន្ត្រីបច្ចេកទេសវិទ្យុឯកជន

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២២ អនក្រ-តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រី ចំនួន ១៩ រូប បំរើការក្នុងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជួយដល់ការងារដឹកនាំរាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោមនេះ ÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សាមីឌី** | **ស៊ុវឌ្ឍនា** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ២-ឯកឧត្តម | **កែប** | **ថុងហ៊ាង** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៣-ឯកឧត្តម | **អ៊ាង** | **សុផល្លែត** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៤-ឯកឧត្តម | **ហ៊ុន** | **ហេង** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៥-ឯកឧត្តម | **វង្សី** | **វិសុត** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៦-ឯកឧត្តម | **ហង់** | **ជួនណារ៉ុន** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៧-ឯកឧត្តម | **ម៉ុក** | **ឆារី** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៨-ឯកឧត្តម | **ប៉ូល** | **ពីខូ** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |
| ៩-ឯកឧត្តម | **ចាន់** | **សុធី** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី |

១០-ឯកឧត្តម **គីម សុភះ** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១១-ឯកឧត្តម **ជាវ សាទី** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១២-ឯកឧត្តម **ម៉ឺន ណៅ** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១៣-ឯកឧត្តម **ចៅ តុល** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១៤-ឯកឧត្តម **តាន់ បញ្ញាធុន** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១៥-ឯកឧត្តម **ហេង សាវឿន** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១៦-ឯកឧត្តម **សុខ សុខៈ** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១៧-ឯកឧត្តម **ឃូ ទីម** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៧ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៨៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ០៦ រូប ដែលបានរួមគ្នាកសាងព្រះវិហារ និង សមិទ្ធផលផ្សេងទៀត ក្នុងវត្តធម្មធារ ហៅវត្តជើងគួន ស្រុកសំរោង ខេត្តតាកែវ ដូចមាននាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណគិរីរោ **ហ៊ីម កុយ** ចៅអធិការវត្តធម្មធារ បច្ច័យ ២១.០០០ USD
២-លោក **តាំង សុភាព** និងអ្នកស្រី **ម៉ិញ កញ្ញារ័ត្ន** ថវិកា ១៣.២៥០ USD
៣-លោក **ម៉ិច ឡេងគី** និងអ្នកស្រី **គង់ សាម៉ុន** ថវិកា ១១.៧២០ USD
៤-លោក **ឈួយ គី** និងអ្នកស្រី **ស្រេង មុយ** ថវិកា ១០.៥៨០ USD
៥-លោក **ជា ប្រួស** និងអ្នកស្រី **ប៉ក់ ពៅ** ថវិកា ១១.០១០ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ខៀវ សារុន** និងអ្នកស្រី **លាង លីអ៊ាង** ថវិកា ៥.២៤៦ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៧១...អនក្រ.

# សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មការស្តារ និងរៀបចំកែលំអកំណាត់ដងស្ទឹងសៀមរាប

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១.—**

ត្រូវបានបង្កើតគណៈកម្មការស្តារ និងរៀបចំកែលំអកំណាត់ដងស្ទឹងសៀមរាប ខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាប្រធាន

២- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ជាអនុប្រធាន

៣- ឯកឧត្តម **អ៊ឹង អឿន** អភិបាលរងទី ១ ខេត្តសៀមរាប ជាអនុប្រធានអចិន្ត្រៃយ៍

៤- ឯកឧត្តម **ឌុច ទននិត្យ** អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

ជាសមាជិក

៥-ឯកឧត្តម **ម៉ិន ហៀន** អគ្គនាយកបច្ចេកទេស ក្រសួងធនធានទឹក និងឧតុនិយម ជាសមាជិក

៦-ឯកឧត្តម **ម៉ិន ណារិទ្ធ** ប្រធានអគ្គនាយក អាជ្ញាធរ អប្សរា ជាសមាជិក

៧-ឯកឧត្តម **គោស៊ី សារឿត** អគ្គនាយក នៃក្រសួងទេសចរណ៍ ជាសមាជិក

**ប្រការ ២.—**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ ពិនិត្យលើទិដ្ឋភាពបច្ចេកទេសលំអិត ដើម្បីស្តារបាតស្ទឹងសៀមរាប ខេត្តសៀមរាប កំណាត់ស្ទឹងចាប់ពីស្ពានអប្សរាររហូតដល់សំណង់ស្ទាក់ទឹកអាងក្រពើដោយផ្អែកលើឯកសារសិក្សាដែលមានស្រាប់របស់អាជ្ញាធរអប្សរា ។

-រៀបចំកែលំអមាត់ស្ទឹងទាំងជើងទេរ និងទាំងខ្នងរាប ទាំងសងខាង ឱ្យទៅជាសួនលំហែសាធារណៈ ។

-លើកគំរោងស្តារបាតស្ទឹង គំរោងកែលំអសួនលំហែមាត់ស្ទឹងទាំងសងខាង ដើម្បីដាក់ ជូន រាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

-តាមដាន និងត្រួតពិនិត្យការអនុវត្តន៍គំរោង

**ប្រការ ៣.—**

គណៈកម្មការនេះមានអនុគណៈកម្មការជំនួយការចំនួន ២ គឺ :

**ក/ អនុគណៈកម្មការបច្ចេកទេស** : មានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ឱុច ទនឌីនូ** អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន

២-លោក **លឹម ទាន់** អគ្គនាយករង នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអនុប្រធាន

៣-លោក **សែ សាមុត** ប្រធាននាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអនុប្រធាន

៤-លោក **ពៅ សុខហៀង** អនុប្រធានមន្ទីរ ដនសស.ទទួលបន្ទុកការងារសុរិយោដី ខេត្តសៀមរាប ជាសមាជិកអចិន្ត្រៃយ៍

៥-លោក **សន គីមសឿ** ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប ជាសមាជិក

៦-លោក **ចេង ផល** ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប ជាសមាជិក

៧-លោក **កង ចន្ធ្រា** អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តសៀមរាប ជាសមាជិក

៨-មន្ត្រីជំនាញក្រសួង ដនស.មួយចំនួនតាមការចាំបាច់ ជាសមាជិក

ខ/ អនុគណៈកម្មការព័ត៌មាន និងផ្សព្វផ្សាយ : មានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ជាប្រធាន

២-ឯកឧត្តម **គោស៊ុំ សារឿត** អគ្គនាយក នៃក្រសួងទេសចរណ៍ ជាអនុប្រធាន

៣-លោក **ជា តន្ត្រី** នាយខុទ្ទកាល័យសាលាខេត្តសៀមរាប ជាសមាជិក

៤-លោក **នូ ផល្លា** អភិបាលស្រុកសៀមរាប ជាសមាជិក

៥-លោក **ទុយ សខ** ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប ជាសមាជិក

៦-លោក **ណាម ពិសិដ្ឋ** ប្រធានមន្ទីរហិរញ្ញវត្ថុ ខេត្តសៀមរាប ជាសមាជិក

**ប្រការ ៤.—**

គណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ហើយមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់និងត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលលើលទ្ធផលការងាររបស់ខ្លួន ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្នុងការចេញលិខិតផ្លូវការនានា ។

**ប្រការ ៥.—**

គណៈកម្មការនេះត្រូវរំសាយជាស្វ័យប្រវត្តិ នៅពេលដែលបានបំពេញភារកិច្ចចប់ជាស្ថាពរ ។

**ប្រការ ៦.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី ក្រសួងទេសចរណ៍ រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី ក្រសួងបរិស្ថាន រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន អភិបាលខេត្តសៀមរាប និងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានី ភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល

-ដូចប្រការ ៦

-ឯកសារ-កាលប្បវត្តិ

DEC.20-11-2001

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២២ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះសំរាប់ដោះស្រាយ ករណី រោងចក្រហ្គោលហ្វាម អ៊ិនធីប្រាយ គ្លីតធីលីមីធីត

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-យោងស្មារតីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០២

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការចំរុះសំរាប់ដោះស្រាយករណីរោងចក្រហ្គោលហ្វាម អ៊ិនធីប្រាយ គ្លីតធីលីមីធីត ស្ថិតនៅឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ដែលមានសមាសភាពដូចតទៅ :-

| | | |
|---|---|---|
| ១-ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវៈនីតិសម្បទា | ជាប្រធាន |
| ២-ឯកឧត្តម **អ៊ិត ប្រាំង** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | អនុប្រធាន |
| ៣-ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-ឯកឧត្តម **ក៏ច ស៊ីថង** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦-ឯកឧត្តម **អ៊ុំ នាង** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |

៧-ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៨-លោក **ឃឹម បូរ** អភិបាលរងទី១ ខេត្តកណ្តាល សមាជិក

៩-លោក **ឃ៉ល់ ចំនួនតារា** មេធាវី នៃអគ្គមេធាវីរាជរដ្ឋាភិបាល សមាជិក

**ប្រការ២** : គណៈកម្មការចំរុះនេះ មានភារកិច្ចដូចតទៅ :-

-ចុះត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវដល់ទីកន្លែង អំពីសភាពការណ៍ មូលហេតុ និងការខូចខាតជាក់ស្តែង នៅក្នុងរោងចក្រហ្គោលហ្វាម អ៊ិនធឺប្រាយ គ្លីតធីលីមីធីត ដែលបណ្តាលមកពីបាតុកម្មហិង្សា កាលពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០២

-វាយតម្លៃនៃការខូចខាតចលនវត្ថុ អចលនវត្ថុ ផលិតផលកាត់ដេរ និងទ្រព្យសម្បត្តិដទៃទៀតរបស់រោងចក្រនេះ

-ធ្វើរបាយការណ៍បូកសរុបអំពីលទ្ធផល នៃការស្រាវជ្រាវ និងលើកវិធានការដោះស្រាយការងារខាងលើ ជូនរាជរដ្ឋាភិបាល ដើម្បីសំរេច ។

**ប្រការ៣** : សមាជិកគណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**ប្រការ៤** : គណៈកម្មការចំរុះនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាជំនួយការ ។

**ប្រការ៥** : គណៈកម្មការចំរុះនេះ ត្រូវរំសាយជាស្វ័យប្រវត្តិ ពេលចប់ភារកិច្ច ។

**ប្រការ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ អភិបាលខេត្តកណ្តាល និងឯកឧត្តម ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៣ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីរៀបចំនិងចូលរួមពិព័រណ៍ពាណិជ្ជកម្មនៅបណ្ដាប្រទេសអាស៊ាន

~~~~~

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## ស ម្រេ ច

**ប្រការ ១:** បង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មASEAN នៅបណ្ដាប្រទេស ជា សមាជិកអាស៊ាន ។

**ប្រការ ២:** គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចតទៅ :

១-ឯកឧត្ដម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធាន
~~~~~

| | | | |
|---|---|---|---|
| ២-ឯកឧត្តម | ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាអនុប្រធាន |
| ៣-ឯកឧត្តម | សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាអនុប្រធាន |
| ៤-ឯកឧត្តម | ម៉ៅ ថូរ៉ា | អគ្គនាយក ក្រសួងពាណិជ្ជកម្ម | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តម | គោស៊ុំ សារឿត | អគ្គនាយក ក្រសួងទេសចរណ៍ | ជាសមាជិក |
| ៦-ឯកឧត្តម | ហង្ស សុត | អគ្គនាយក ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាសមាជិក |
| ៧-ឯកឧត្តម | គុំ សារូន | អគ្គនាយក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៨-លោក | ឆេង សារឿន | អគ្គនាយករង ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៩-លោក | កែ ផៃ | អគ្គនាយករង ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ១០-លោក | ម៉ុន ឈាង | អគ្គនាយករង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ១១-លោក | ស៊ឹម ទ៉ា | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១២-លោក | ឈឹក សុខុម | ប្រធាននាយកដ្ឋានទីផ្សារ និងផ្សព្វផ្សាយ ក្រសួងទេសចរណ៍ | ជាសមាជិក |
| ១៣-លោក | ឌែក សារិន | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាសមាជិក |
| ១៤-លោក | ញាណ ទិបុល | អនុប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ១៦-លោក | ហេង សោភ័ណ្ឌ | អនុប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ជាសមាជិក |
| ១៧-លោក | ជា គៀត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និង ជំរុញវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១៨-លោក | អៀង ស៊ុនលី | អនុប្រធាននាយកដ្ឋានថវិការនិយ័តកម្ម និងហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋាននៅនាយកដ្ឋានជំរុញការនាំចេញ នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៤ :** គណៈកម្មការអន្តរក្រសួងនេះ មានភារៈកិច្ចដូចតទៅ :

- ចូលរួមពិព័រណ៍ពាណិជ្ជកម្ម ASEAN នៅទីក្រុងបាងកក ឆ្នាំ២០០២ ក៏ដូចជាពិព័រណ៍ ពាណិជ្ជកម្ម ASEAN នាឆ្នាំបន្តបន្ទាប់ ត្រូវស្ថិតនៅជានិរន្តន៍ ដើម្បីបំរើការតាំងពិព័រណ៍ពាណិជ្ជកម្ម ASEAN
- ធ្វើទំនាក់ទំនងជាមួយភាគីម្ចាស់ផ្ទះ ដើម្បីចូលរួមពិព័រណ៍ពាណិជ្ជកម្ម ASEAN
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អង្គការអន្តរជាតិ និងក្រុមហ៊ុននានាដែលពាក់ព័ន្ធ ដើម្បីត្រៀមលក្ខណៈក្នុងការចូលរួមពិព័រណ៍ពាណិជ្ជកម្ម ASEAN នេះ
- ទទួលខុសត្រូវ និងចាត់ចែងពីការងាររៀបចំសាងសង់ស្តង់ (NATIONAL PAVILLION) និងសំរបសំរួលការទទួលខុសត្រូវចំពោះស្តង់ឯកជន (PRIVATE SECTOR)
- ជំរុញការតាំងពិព័រណ៍របស់ព្រះរាជាណាចក្រកម្ពុជាយើង អោយបានទទួលជោគជ័យយ៉ាងត្រចះត្រចង់នៅទីក្រុងបាងកកខាងមុខនេះ ក៏ដូចជាពិព័រណ៍ពាណិជ្ជកម្មអាស៊ាន នាឆ្នាំបន្តបន្ទាប់នៅបណ្តាប្រទេសជាសមាជិកអាស៊ាន
- លើកយោបល់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសំរេចក្នុងករណីចាំបាច់ និងធ្វើរបាយការណ៍បូកសរុបលទ្ធផលជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងពាក់ព័ន្ធ នៅពេលពិព័រណ៍ពាណិជ្ជកម្មមួយលើកៗបញ្ចប់ ។

**ប្រការ ៥ :** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យ និងផ្តល់ថវិកាសំរាប់ចំណាយក្នុងការចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្មនេះ ។

**ប្រការ ៦ :** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួន សំរាប់ជំនួយការងារ ។

**ប្រការ ៧ :** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ដែលពាក់ព័ន្ធ និង ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានចែងឈ្មោះ

ក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ.....០៦.....សរណន

# សារាចរណែនាំ
## ស្តីពី
## ការរៀបចំបុណ្យវិសាខបូជា
## និង
## ព្រះរាជពិធីច្រត់ព្រះនង្គ័ល

xxxxx

✷បុណ្យវិសាខបូជា គឺជាបុណ្យមួយក្នុងបណ្តាបុណ្យធំៗទាំងឡាយ ក្នុងព្រះពុទ្ធសាសនា ដែលប្រទេសកាន់ព្រះពុទ្ធសាសនាលើសកលលោក តែងប្រារព្ធធ្វើពុំដែលខាន ។

ពិធីនេះ ប្រារព្ធឡើងដើម្បីរំឭកដល់ថ្ងៃជាមហាមង្គលទាំងបី ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ប្រសូតចាកឧទរព្រះមាតាផង ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណផង និងទ្រង់រំលត់ខន្ធចូលកាន់ព្រះបរមនិព្វានផង ។

ចំពោះពុទ្ធសាសនិកខ្មែរយើង ក៏តែងប្រារព្ធធ្វើបុណ្យវិសាខបូជាជារៀងរាល់ឆ្នាំ នៅគ្រប់វត្តអារាមទូទាំងប្រទេស ដោយចាត់ទុកថា នោះជាមហាកុសលដ៏ថ្លៃថ្លាបំផុត ។

រីឯរាជរដ្ឋាភិបាល ក៏បានចាត់ចែងរៀបចំពិធីបុណ្យនេះជាផ្លូវការ នៅបរិវេណព្រះសក្យមុនីចេតិយ មុខរាជាយស្ម័យយានកម្ពុជា ដោយមានថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ អ្នកមុខអ្នកការ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ពុទ្ធបរិស័ទដ៏ច្រើនកុះករចូលរួម ស្របតាមស្មារតីរដ្ឋធម្មនុញ្ញ ដែលបានចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

ឆ្នាំនេះ បុណ្យវិសាខបូជា នឹងត្រូវប្រព្រឹត្តទៅរយៈពេល ២ថ្ងៃគឺ ថ្ងៃសុក្រ ១៥កើត និងថ្ងៃសៅរ៍ ១រោច ខែពិសាខ ព.ស ២៥៤៦ ត្រូវនឹងថ្ងៃទី ២៦ និងទី ២៧ ខែ មេសា ឆ្នាំ ២០០២ តាមកម្មវិធី ជាក់ស្តែង ។

✷ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាព្រះរាជបវេណីដ៏សំខាន់ ក្នុងបណ្តាព្រះរាជពិធីបុណ្យទ្វាទសមាសប្រចាំឆ្នាំ ចាត់ទុកថាជាវប្បមង្គលមួយដ៏ប្រសើររបស់ប្រជារាស្ត្រខ្មែរ ដែលព្រះមហាក្សត្រគ្រប់ព្រះអង្គ តែងដឹកនាំប្រារព្ធធ្វើពុំដែលខាន តាំងពីបុរាណកាលរៀងមក ។

ព្រះរាជពិធីនេះ ប្រព្រឹត្តឡើងដើម្បីជាមង្គលឧទ្ទិសដល់ការធ្វើស្រែចម្ការ និងបួងសួងដល់វត្ថុស័ក្តិសិទ្ធឱ្យបង្អុរទឹកភ្លៀងបរិបូណ៌តាមរដូវកាល អាចបំរើឱ្យវិស័យកសិកម្មគ្រប់ប្រភេទទទួលបានលទ្ធផលខ្ពស់ របស់ប្រជាកសិករយើង ។

ព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំនេះ ប្រព្រឹត្តទៅរយៈពេល ៤ថ្ងៃ គឺចាប់ពីថ្ងៃ ១-២-៣ រោច ខែពិសាខ ត្រូវនឹងថ្ងៃទី ២៧-២៨-២៩ ខែមេសា ឆ្នាំ២០០២ ជាទិវាតាំងពិធីច្រត់ព្រះនង្គ័ល ជាភារកិច្ចរបស់លោកអាចារ្យ និង

ក្រុមបារគូ ។ ឯថ្ងៃអង្គារ ៤រោច ខែពិសាខ ត្រូវនឹងថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០២ ជាព្រះរាជពិធីច្រត់ព្រះនង្គ័ល ផ្លូវការ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ។

ដើម្បីញ៉ាំងឱ្យពិធីទាំងពីរនេះប្រព្រឹត្តទៅយ៉ាងឧឡារិក អធិកអធម សមស្របតាមអត្ថន័យ និងខ្លឹមសារដូចខាងលើ រាជរដ្ឋាភិបាល ដាក់ចេញសារាចរណែនាំដូចខាងក្រោម :

## ១_អំពីបុណ្យវិសាខបូជា

-ក្រសួងព្រះបរមរាជវាំង ចាត់តាំងព្រះរាជពិធីបុណ្យវិសាខបូជានៅក្នុងព្រះបរមរាជវាំង តាមព្រះរាជបវេណី និងតាមការសព្វព្រះរាជហឫទ័យរបស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីគោរព ។

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងធម្មការ និងសាសនា និងសាលាក្រុងភ្នំពេញ ចាត់តាំងពិធីបុណ្យវិសាខបូជាជាផ្លូវការ នៅបរិវេណព្រះសក្យមុនីចេតិយ មុខរាជាយស្ម័យយានកម្ពុជា ដោយមានការអញ្ជើញថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងពុទ្ធបរិស័ទចូលរួមឱ្យបានច្រើនកុះករតាមកម្មវិធីជាក់ស្តែង ។

-គ្រប់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ត្រូវរៀបចំឱ្យមានកម្មវិធីបុណ្យវិសាខបូជាជាផ្លូវការ នៅទីវត្តណាមួយដែលអាចដំណើរការបានដោយនិមន្តមន្ត្រីសង្ឃ អញ្ជើញថ្នាក់ដឹកនាំ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ មន្ត្រីរាជការក្រោមឱវាទ អ្នកមុខអ្នកការ ព្រមទាំងពុទ្ធបរិស័ទចូលរួមឱ្យបានច្រើនកុះករ ។

-ក្រសួងធម្មការ និងសាសនា ត្រូវណែនាំគ្រប់អង្គភាពក្រោមឱវាទ សហការជាមួយពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ ចាត់តាំងពិធីបុណ្យវិសាខបូជាឱ្យបានផុលផុស ដើម្បីលើកកំពស់តួនាទីដ៏សំខាន់របស់ព្រះពុទ្ធសាសនា និងប្រពៃណីដ៏ល្អរបស់ជាតិយើង ។

## ២_អំពីព្រះរាជពិធីច្រត់ព្រះនង្គ័ល

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សាលាក្រុងភ្នំពេញ និងក្រសួងពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងព្រះបរមរាជវាំង ចាត់តាំងព្រះរាជពិធីច្រត់ព្រះនង្គ័លនៅទីព្រះស្រែវាលព្រះមេរុ ឱ្យបានឧឡារិកអធិកអធម ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ដោយមានការយាងនិងអញ្ជើញចូលរួម ពីព្រះរាជវង្សានុវង្ស ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងប្រជារាស្ត្រតាមចំនួនកំណត់ជាក់ស្តែង ដើម្បីរក្សាឱ្យបានគង់វង្សនូវព្រះរាជបវេណីពីបូរាណរបស់ព្រះអតីតមហាក្សត្រនៃយើង ។

-ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយសម្ភារៈ ថវិកាសម្រាប់បំរើពិធីបុណ្យទាំងពីរឱ្យបានទាន់ពេលវេលា ធានារូបភាពចាត់តាំងស្របតាមគោលបំណង និងសំណូមពរ ។

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចាត់តាំងក្រុមសិល្បៈសំដែងជូនមហាជនទស្សនា អបអរសាទរព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅថ្ងៃអង្គារ ទី ៣០ ខែ មេសា ឆ្នាំ ២០០២ នៅទីព្រះស្រែវាលព្រះមេរុ ។

-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាព ក្រោមឱវាទ ឱ្យសហការការពាររក្សាសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ធានាសុវត្ថិភាព ក្នុងបុណ្យទាំងពីរឱ្យបានល្អប្រសើរ ។

-ក្រសួងព័ត៌មាន ត្រូវចាត់តាំងបណ្ដាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ចុះធ្វើសកម្មភាពយកព័ត៌មាន ដោយថ្លៃប្រឌិត ធ្វើការផ្សព្វផ្សាយទូលាយ ទាំងរូបភាពចាត់តាំង និងទាំងខ្លឹមសារនៃពិធីបុណ្យទាំងពីរ មុន-ក្រោយ និងក្នុងពេលប្រារព្ធពិធីបុណ្យ ។

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងមន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងប្រជាពលរដ្ឋ ចូលរួមតាមការកំណត់ និងត្រូវមានកម្មវិធីជាក់ស្ដែង ព្រមទាំងបំផុសឱ្យតុបតែងលំអ ចងបដា ពាក្យស្លោក ទង់ជាតិ នៅតាមអគារសាធារណៈ រោងចក្រ សហគ្រាស និងគ្រប់គេហដ្ឋាន អបអរសាទរបុណ្យទាំងពីរខាងលើ ឱ្យបានល្អប្រសើរ ស័ក្ដិសមជាទិវាបុណ្យជាតិ ដ៏រុងរឿង ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន គ្រប់ស្ថាប័ន អង្គភាព រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ទូទាំងប្រទេស នឹងចាត់តាំងអនុវត្តតាមស្មារតីសារាចរណែនាំនេះ សម្រេចបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង "ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

## ពាក្យស្លោកសំរាប់បុណ្យវិសាខបូជា

-----

-អបអរសាទរពិធីបុណ្យវិសាខបូជា ឆ្នាំមមី ចត្វាស័ក ព.ស ២៥៤៦

-សូមថ្វាយព្រះពរសម្តេចឪ សម្តេចម៉ែ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់

-ជយោ ! ព្រះរាជាណាចក្រកម្ពុជា

-ជាតិ សាសនា ព្រះមហាក្សត្រ

-ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ

-នត្ថិ សន្តិ បរំ សុខំ គ្មានសុខឯណាស្មើនឹងសេចក្តីស្ងប់

-សុខោ បុញ្ញស្ស ឧច្ចយោ ការសន្សំបុណ្យនាំមកនូវសេចក្តីសុខ

-អហិង្សា ជាគោលការណ៍រួមនៃព្រះពុទ្ធសាសនា

-សុភមង្គល និងអភិវឌ្ឍន៍ ជាសំណូមពរដ៏ពិសិដ្ឋរបស់ព្រះពុទ្ធសាសនា

-សូមព្រះធម៌របស់ព្រះពុទ្ធបរមគ្រូជ្រួតជ្រាបគ្រប់មនុស្សទូទៅ

-ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍

-សម្តេចឪ សម្តេចម៉ែ ជាព្រះរាជអគ្គពុទ្ធសាសនូបត្ថម្ភក៍

## ពាក្យស្លោកសំរាប់ពិធីច្រត់ព្រះនង្គ័ល

-----

១- អបអរសាទរ ព្រះរាជពិធីច្រត់ព្រះនង្គ័ល " ៣០-០៤-២០០២ "

២- ជយោ ! សម្តេចព្រះបិតាកសិកម្មជាតិ

៣- កសិកម្ម ជាមូលដ្ឋាននៃសេដ្ឋកិច្ចជាតិ

៤- អភិវឌ្ឍន៍វិស័យកសិកម្ម គឺអភិវឌ្ឍន៍សង្គមជាតិ

៥- កសិកម្មល្អតលាស់ ជីវភាពប្រជាកសិកររីកចំរើន

៦- រួមគ្នាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម

៧- ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាវប្បធម៌ដ៏ឧត្តម

៨-សូមថ្វាយព្រះពរ សម្តេចឪ សម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ

៩-ជយោ ! រាជរដ្ឋាភិបាលសេដ្ឋកិច្ច

១០-ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ១៨.សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារអភិវឌ្ឍន៍សង្គមកិច្ច

## នៅទីស្តីការគណៈរដ្ឋមន្ត្រី

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច
- យោងលិខិតលេខ ១១ ក.អ.ស ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារអភិវឌ្ឍន៍សង្គមកិច្ចនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចតទៅ ÷

១. លោក **ខឹម ទិសិដ្ឋ** ប្រធាននាយកដ្ឋានអប់រំ វប្បធម៌ និងសង្គមកិច្ច ជាប្រធាន

២. លោក **ទេព ទូច** ប្រធានការិយាល័យនាយកដ្ឋានពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងធនាគារ ជាសមាជិក

៣. លោក **ញឹម បូខារ៉ន** មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាសមាជិក

**ប្រការ ២ :** លោកប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នាយកដ្ឋានពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងធនាគារ នាយកដ្ឋានផែនការ ព្រមទាំងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០២

**ជ.ទេសរដ្ឋមន្ត្រី**

**ស៊ុំ ម៉ានិត**

**កន្លែងទទួល:**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧២៦ សហវ

# ប្រកាស

## ស្ដីពី

## ការផ្លាស់ប្ដូរសមាជិកក្រុមការងារ
## សំរាប់គំរោងអភិវឌ្ឍន៍កសិកម្មក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445-CAM (SF)

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញកិច្ចព្រមព្រៀងខ្ចីបុល រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445-CAM (SF) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៦

-បានឃើញប្រកាសលេខ ៤០៦ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីការបង្កើតក្រុមការងារសំរាប់គំរោងអភិវឌ្ឍន៍កសិកម្ម ក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445-CAM (SF)

-បានឃើញប្រកាសលេខ ៤៧០ សហវ.វស ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០០ របស់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីការបន្ថែមសមាជិកក្រុមការងារសំរាប់គំរោងអភិវឌ្ឍន៍កសិកម្មក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ1445-CAM (SF)

-បានឃើញភាពចាំបាច់របស់ក្រសួង

# សំរេច

**ប្រការ១:** ផ្លាស់ប្តូរសមាជិកចំនួន០២រូប ក្នុងក្រុមការងារសំរាប់គំរោងការអភិវឌ្ឍន៍កសិកម្ម" Agriculture Sectors Program Loan" ក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445-CAM (SF) ពីឈ្មោះ :

១ - លោក អ៊ុយ ឈឺន ទៅលោក ឈួន ស៊ីរីទ្ធិ អនុប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី

២ - លោក ឃុន ហ្សូលីន ទៅលោក ទេព សៀង មន្ត្រីការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី

**ប្រការ២:** ភារកិច្ចរបស់សមាជិកដែលផ្លាស់ចូលថ្មីនេះ មានចែងនៅក្នុង" ប្រការ២" នៃប្រកាសលេខ ៨០ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២ ដូចបានយោងខាងលើ ។

**ប្រការ៣:** អគ្គលេខាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០០២

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចំឡងជូន:**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- ក្រសួងធនធានទឹក និងឧតុនិយម
- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៤៥ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០០២

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញឯកសារចក្ខុវិស័យនិងផែនការសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុពីឆ្នាំ២០០១-២០១០ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០១

-បានឃើញលិខិតរបស់ក្រសួងពាណិជ្ជកម្មលេខ ២៦៣៩ MoC/M 2001 ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១

-បានឃើញលិខិតរបស់ធនាគារជាតិលេខ ធ ៦.០១.៥២២ លស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០១

-បានឃើញស្មារតីនៃកិច្ចចរចារវាងតំណាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១

-បានឃើញលិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ ២៥៤៧/០១ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០១

-បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០១

# សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការដឹកនាំ (Steering Committee) និង ក្រុមការងារបច្ចេកទេស (Technical Working Group) សំរាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ (Financial Sector Development) ដែលមានសមាសភាពដូចខាងក្រោម:

**ក. គណៈកម្មាធិការដឹកនាំ**

| | | |
|---|---|---|
| ១-ឯកឧត្តម **ជា ចាន់តូ** | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ស៊ឺ សន្តិសិទ្ធ** | អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា | លេខាធិការ |
| ៤-ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៥-លោកជំទាវ **តាល់ ណែរអ៊ីម** | អគ្គនាយកធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៦-លោក **ពេជ្រ ឫទ្ធី** | អគ្គនាយករងបច្ចេកទេស ក្រសួងពាណិជ្ជកម្ម | សមាជិក |

**ខ. ក្រុមការងារបច្ចេកទេស**

| | | |
|---|---|---|
| ១- លោកជំទាវ **តាល់ ណែរអ៊ីម** | អគ្គនាយកធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- លោក **ម៉ី ទ័រន់** | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- លោកស្រី **ខូន សុខា** | អនុប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជា | លេខាធិការ |
| ៤- លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥-លោក **ផាន់ ហូរ** | ប្រធាននាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៦-លោក **អន សុផាណារ៉ា** | ប្រធាននាយកដ្ឋាននីតិកម្មនិងច្បាប់វិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧-លោក **ម៉ិញ ឋានកុសល** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ៨-លោក **គាំង សុជាតិ** | អនុប្រធាននាយកដ្ឋានគណនេយ្យ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩-លោក **អ៊ុន ចុនថា** | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០-លោក **សេស សុធីរ** | ប្រធានការិយាល័យគ្រប់គ្រងអាជីវកម្មនិងប្រកួតប្រជែង ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១-លោក **អ៊ុល ណារ៉ាត់** | ប្រធានការិយាល័យគ្រប់គ្រងជំនួយពហុភាគី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

**ប្រការ ២ :** គណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមានភារកិច្ចដូចខាងក្រោម :

- សំរបសំរួលចំពោះជំនួយឧបត្ថម្ភដែលម្ចាស់ជំនួយបានផ្តល់សំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- តាមដាននិងជំរុញការអនុវត្តន៍ផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ពិនិត្យនិងផ្តល់ការណែនាំស្តីពីគោលនយោបាយហិរញ្ញវត្ថុនិងថវិកាសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- រៀបចំយុទ្ធសាស្ត្រផែនការសកម្មភាព និងយន្តការគៀងគរប្រភពធនធានព្រមទាំងការបែងចែកធនធានហិរញ្ញវត្ថុសំរាប់វិស័យនេះ
- ពិនិត្យនិងពង្រឹងប្រព័ន្ធរៀបចំផែនការថវិកា និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ដោយសំរបសំរួល ផែនការទាំងនេះទៅនឹងផែនការកសាងសមត្ថភាពក្នុងវិស័យអភិវឌ្ឍន៍ហិរញ្ញវត្ថុ
- ធ្វើការចរចា និងចុះហត្ថលេខាលើអនុស្សារណៈនានាពាក់ព័ន្ធជាមួយជំនួយបច្ចេកទេស និងឥណទានជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលើវិស័យនេះ
- ធ្វើរបាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជូនរាជរដ្ឋាភិបាលអំពីការវិវត្តន៍នៃដំណើរការអនុវត្តន៍ផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។

**ប្រការ ៣ :** ក្រុមការងារបច្ចេកទេស ត្រូវបំពេញការងារក្រោមការណែនាំរបស់គណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងមានភារកិច្ចដូចតទៅ :

- ធ្វើការងារជាមួយក្រុមជំនួយបច្ចេកទេស ដើម្បីជំរុញការអនុវត្តន៍ផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និង ក្នុងកិច្ចព្រមព្រៀងឥណទានឱ្យបានជោគជ័យ
- ជំនួយការឱ្យគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក្នុងការតាមដាននិងត្រួតពិនិត្យនូវការអនុវត្តន៍ការងារប្រចាំថ្ងៃរបស់ក្រុមប្រតិបត្តិប្រចាំនៅសាមីស្ថាប័ននីមួយៗ

- សំរបសំរួលឱ្យមានការឯកភាពគ្នារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើរាល់បញ្ហាដែលទាក់ទងនឹង :
  - ហិរញ្ញប្បទានសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
  - ការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និង
  - ការត្រួតពិនិត្យលើការអនុវត្តន៍ការងារគ្រប់គ្រងហិរញ្ញវត្ថុដែលកំពុងប្រើប្រាស់
- ធ្វើរបាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុអំពីការវិវត្តន៍នៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

**ប្រការ ៤ :** ក្រសួង ស្ថាប័នពាក់ព័ន្ធខាងលើ ត្រូវបង្កើតក្រុមប្រតិបត្តិ ( Task force) របស់ខ្លួនដើម្បីអនុវត្តគំរោងប្រចាំថ្ងៃរបស់ក្រសួង ឬស្ថាប័នសាមុី ដែលមានចែងក្នុងឯកសារចក្ខុវិស័យនិងផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងជាចំណុចសំរាប់ធ្វើទំនាក់ទំនងអន្តរស្ថាប័នលើការងារនេះ ។

**ប្រការ ៥ :** គណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសមានលេខាធិការដ្ឋាននៅធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៦ :** សមាជិកនៃគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសទាំងអស់ត្រូវចូលរួមប្រជុំពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុតាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ ៧ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងសាមុីខ្លួនដូចប្រការ០១ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំឡងជូន :**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីជូនជ្រាប " ដូចក្នុងប្រការ ៣
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ១១១ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០២

## ប្រកាស
## ស្តីពី
## ស្ថានភាពរោងចក្រកាត់ដេរ Eastfull Footwear MFG Co., Ltd.
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ចាត់ទុកថាបាន បិទទ្វារជាបណ្តោះអាសន្ន រោងចក្រកាត់ដេរសំលៀកបំពាក់ **Eastfull Footwear MFG Co., Ltd.** ដែលគ្មានសកម្មភាពចំពោះមុខដោយមានមូលហេតុផ្សេងៗ ប៉ុន្តែឧបករណ៍ផលិតកម្ម និង គ្រឿងម៉ាស៊ីននៅ រក្សាដដែលហើយកម្មករត្រូវបានបញ្ឈប់ ពីការងារជាបណ្តោះអាសន្ន។ រោងចក្រកាត់ដេរសំលៀកបំពាក់នោះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធ នាំចេញ នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការបែងចែកកូតាផ្សេងៗ (បើមាន ) នឹងត្រូវផ្អាក ។ រោងចក្រខាងលើនេះ អាចទទួលបានសិទ្ធនាំចេញសាជាថ្មី ប្រសិនបើ

រោងចក្រទាំងនោះបន្តសកម្មភាពរបស់ ខ្លួនវិញក្នុងរយៈពេល ៣ ខែបន្ទាប់ ហើយកូតាឆ្នាំ ២០០០ ជាមូលដ្ឋាន នឹងត្រូវបានប្រគល់ជូនវិញ ។ ប្រសិនបើរោងចក្រទាំងនោះមិនបានបន្តសកម្មភាពរបស់ខ្លួនក្នុងរយៈពេល ៣ ខែបន្ទាប់ រោងចក្រទាំងនោះនឹងត្រូវចាត់ទុកថាបានបិទទ្វារជាស្ថាពរ ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់គេនឹងត្រូវឆូត ពណ៌ក្រហម និង ចារថាបានបិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, នាយកដ្ឋាននីតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតិយជន នៅកម្ពុជា ព្រមទាំងបំណុលរបស់គេ ចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាន នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននីតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

ចម្លងជូន :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនីតិសម្បទា
- ស្ថានទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ

File: *Prakas on Temporary closed Eastfull Footwear MFG Co.; Ltd*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

~~~~~~~~~

**ក្រសួងមហាផ្ទៃ និងក្រសួងផែនការ**

**លេខ :....៥៥.............ប្រក**

## ប្រកាសណែនាំអន្តរក្រសួង

## ស្តីពី

## ការប្រើប្រាស់សេចក្តីណែនាំពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងគំរូសៀវភៅផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគឃុំ សង្កាត់ ៣ឆ្នាំ រំកិល (២០០៣-២០០៥)

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងផែនការ

- អនុវត្តតាមខ្លឹមសារប្រការ៣០ នៃប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការលេខ ០៩៨ ប្រក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់

## សំរេច

**ប្រការ ១:** ប្រកាសណែនាំនេះរៀបចំឡើងក្នុងគោលបំណងផ្តល់ជំនួយបច្ចេកទេស ដល់គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ ក្នុងការអនុវត្តន៍ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រយៈពេល ៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល (២០០៣-២០០៥) ។

**ប្រការ២:** គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ និងគ្រប់អ្នកពាក់ព័ន្ធត្រូវធ្វើការរៀបចំ និងចូលរួមកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រយៈពេល ៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគឃុំ សង្កាត់ ៣ឆ្នាំរំកិល (២០០៣-២០០៥) តាមខ្លឹមសារនៃសេចក្តីណែនាំស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃប្រកាសណែនាំនេះ។

**ប្រការ៣:** គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ និងគ្រប់អ្នកពាក់ព័ន្ធត្រូវធ្វើការចងក្រងសៀវភៅផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រយៈពេល ៥ឆ្នាំ (២០០៣-២០០៧) និងកម្មវិធីវិនិយោគឃុំ សង្កាត់
~~~~~~~~~

៣ឆ្នាំរំកិល (២០០៣-២០០៥ ) តាមខ្ទឹមសារទំរង់គំរូមាតិកា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃប្រកាសណែនាំនេះ ។

**ប្រការ៤:** ប្រកាសណែនាំនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ...... ខែ ...... ឆ្នាំ ២០០២

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** **រដ្ឋមន្ត្រីក្រសួងផែនការ**

ស ខេង យូ ហុកគ្រី ឆាយ ថន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សមាជិក"គ.ឃ.ស"

" ដើម្បីជូនជ្រាប "

- សាលាខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់

"ដើម្បីមុខការ"